# អង្គការសហប្រជាជាតិ

# សេចក្តីពន្យល់ទូទៅ

# អំពី

# សេរីភាពនៃគំនិត និងការសម្តែងមតិ

អនុម័តដោយគណៈកម្មាធិការសិទ្ធិមនុស្ស

នៅសម័យប្រជុំលើកទី១០២របស់ខ្លួន កាលពីខែកក្កដា ឆ្នាំ២០១១

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា

# អង្គការសហប្រជាជាតិ

# សេចក្តីពន្យល់ទូទៅ

# អំពី

# សេរីភាពនៃគំនិត និងការសម្តែងមតិ

អនុម័តដោយគណៈកម្មាធិការសិទ្ធិមនុស្ស

នៅសម័យប្រជុំលើកទី១០២របស់ខ្លួន កាលពីខែកក្កដា ឆ្នាំ២០១១

សេចក្តីពន្យល់ទូទៅលេខ៣៤

កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

មាត្រា១៩៖ សេរីភាពនៃគំនិត និងការសម្តែងមតិ

UNITED NATIONS HUMAN RIGHTS
OFFICE OF THE HIGH COMMISSIONER
Cambodia

ខែវិច្ឆិកា ឆ្នាំ២០១២

# មាតិកា

ទំព័រ

១-សេចក្តីផ្តើម.....................................................................................៥

២-កំណត់សំគាល់ទូទៅ.......................................................................១០

៣-សេរីភាពនៃគំនិត...........................................................................១៤

៤-សេរីភាពនៃការបញ្ចេញមតិ ...........................................................១៥

៥-សេរីភាពនៃការបញ្ចេញមតិ និងប្រព័ន្ធសារព័ត៌មាន ............................១៨

៦-សិទ្ធិទទួលបានព័ត៌មាន .................................................................២០

៧-សេរីភាពនៃការបញ្ចេញមតិ និងសិទ្ធិនយោបាយ...............................២៣

៨-ការអនុវត្តមាត្រា១៩(៣) ................................................................២៤

៩-វិសាលភាពមានកំរិតនៃការរិតត្បិតលើសេរីភាព

នៃការបញ្ចេញមតិក្នុងវិស័យជាក់លាក់មួយចំនួន.................................. ៣៦

១០-ទំនាក់ទំនងរវាងមាត្រា១៩ និងមាត្រា២០.................................... ៤៧

៚*៚

# សេចក្តីផ្តើម

សេរីភាពនៃគំនិត និងការបញ្ចេញមតិ គឺជាសិទ្ធិមនុស្សជាមូលដ្ឋាន មួយ ដែលត្រូវបានប្រកាសនៅក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិ មនុស្ស ហើយ ត្រូវបានការពារក្រោមកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពល រដ្ឋ និងសិទ្ធិនយោបាយ។

ការគោរពសិទ្ធិសេរីភាពនៃគំនិត និងការបញ្ចេញមតិ គឺមានសារៈសំខាន់ មិនត្រឹមតែសម្រាប់ការអភិវឌ្ឍបុគ្គលឲ្យបានពេញលេញប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងសម្រាប់សង្គមមួយផងដែរ ហើយក៏ជាមូលដ្ឋានគ្រឹះសម្រាប់គ្រប់សង្គមប្រជាធិបតេយ្យសេរី។ សេរីភាពទាំងពីរនេះ ទាក់ទងគ្នាយ៉ាងជិតស្និទ្ធ ដែលក្នុងនោះ សេរីភាពនៃការបញ្ចេញមតិ គឺជាមធ្យោ បាយសម្រាប់ការផ្លាស់ប្តូរ និងការបង្កើតគំនិត ដើម្បីអាចស្តែងចេញជាក់ស្តែង។

ការទទួលបានសេរីភាពនៃគំនិត និងការបញ្ចេញមតិ គឺកាន់តែមាន សារៈសំខាន់ថែមទៀត ដោយសារតែ វាជាលក្ខខណ្ឌដំបូងគេដែលមិនអាចជៀសបាន សម្រាប់ការធ្វើឲ្យសម្រេចបាននូវសិទ្ធិមនុស្សផ្សេងៗ ជាច្រើនទៀត។ ប្រសិនបើរដ្ឋមួយ មិនគោរពសេរីភាពនៃគំនិត និងការបញ្ចេញមតិ នេះអាចនឹងធ្វើប៉ះពាល់ដល់ការអនុវត្តសិទ្ធិជាមូលដ្ឋានដទៃទៀត ដែលបុគ្គលទាំងឡាយត្រូវទទួលបាន ដូចជាសេរីភាពនៃការជួបប្រជុំ និងសមាគម។ ការគោរពសិទ្ធិចូលរួមក្នុងកិច្ចការសាធារណៈ និងសិទ្ធិបោះឆ្នោត ក៏មានទំនាក់ទំនងគ្នាផងដែរ ជាមួយនឹងការទទួលបានសេរីភាពនៃគំនិត និងការបញ្ចេញមតិ។

នៅឆ្នាំ១៩៩២ រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់សច្ចាប័នលើកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលនេះមានន័យថា កម្ពុជាត្រូវបានជាប់កាតព្វកិច្ចតាមផ្លូវច្បាប់ដោយបទបញ្ញត្តិទាំងឡាយ នៃកតិកាសញ្ញានេះ។ មាត្រា៣១ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាបានចែងបន្ថែមទៀតឲ្យរដ្ឋទទួលស្គាល់ និងគោរពសិទ្ធិមនុស្សទាំងឡាយ ដែលមានចែងក្នុងសន្ធិសញ្ញា

សិទ្ធិមនុស្សអន្តរជាតិ។ ហេតុដូច្នេះ កម្ពុជា គួរតែយកមកអនុវត្តឲ្យមានប្រសិទ្ធភាពនូវការបកស្រាយ និងការបំភ្លឺ ទៅលើបញ្ញត្តិទាំងឡាយតាមមាត្រា១៩ នៃកតិកាសញ្ញានេះ ដូចមានកំណត់នៅក្នុងសេចក្តីពន្យល់ទូទៅលេខ៣៤។ ច្បាប់ជាតិ ក៏បានធានាការពារផងដែរដល់សេរីភាពនៃការបញ្ចេញមតិរបស់ពលរដ្ឋកម្ពុជាគ្រប់រូប តាមមាត្រា៤១ នៃរដ្ឋធម្មនុញ្ញកម្ពុជា ដែលចែងថា "ប្រជាពលរដ្ឋខ្មែរ មានសេរីភាពនៃការបញ្ចេញមតិ សេរីភាពខាងសារព័ត៌មាន ខាងការបោះពុម្ពផ្សាយ និងសេរីភាពនៃការជួបប្រជុំ"។

*តើសេរីភាពនៃគំនិត និងការបញ្ចេញមតិ មានន័យយ៉ាងដូចម្តេច តាមមាត្រា១៩ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ?*

ដូចមានចែងក្នុងមាត្រា១៩ នៃកតិកាសញ្ញានេះ សិទ្ធិសេរីភាពនៃគំនិត និងការបញ្ចេញមតិ មានធាតុផ្សំខុសៗគ្នាចំនួនបីគឺ៖

(ក) សិទ្ធិប្រកាន់យកគំនិតរបស់ខ្លួនដោយគ្មានការជ្រៀតជ្រែក

(ខ) សិទ្ធិស្វែងរក និងទទួលព័ត៌មាន និងសិទ្ធិទទួលបានព័ត៌មាន និង

(គ) សិទ្ធិបញ្ជូនព័ត៌មាន និងគំនិតសព្វបែបយ៉ាង ដោយមិនគិតពីព្រំដែន ទោះជាដោយផ្ទាល់មាត់ ដោយសរសេរ ឬដោយបោះពុម្ព តាមទម្រង់សិល្បៈក្តី ឬតាមមធ្យោបាយផ្សព្វផ្សាយដទៃណាមួយក្តី តាមការជ្រើសរើសរបស់ខ្លួន។

សេចក្តីពន្យល់ទូទៅលេខ៣៤ ផ្តល់ព័ត៌មានបន្ថែមទៀតអំពីនិយមន័យនៃធាតុផ្សំនីមួយៗក្នុងចំណោមធាតុផ្សំទាំងនេះ។

*តើរដ្ឋាភិបាលត្រូវមានកាតព្វកិច្ចអ្វីខ្លះ ទាក់ទងនឹងការគោរពសិទ្ធិសេរីភាពនៃគំនិត និងសេរីភាពនៃការបញ្ចេញមតិ?*

ដូចមានចែងយ៉ាងជាក់លាក់តាមមាត្រា១៩ សិទ្ធិសេរីភាពនៃគំនិត និងការបញ្ចេញមតិ ដូចសិទ្ធិទាំង អស់ដែរ ដាក់កាតព្វកិច្ចតាមផ្លូវច្បាប់ទៅលើរដ្ឋាភិបាល មានដូចជា៖

(ក) ត្រូវគោរពសិទ្ធិនោះ ឬមិនត្រូវជ្រៀត ជ្រែកដល់ការទទួលបានសិទ្ធិនោះឡើយ

(ខ) ត្រូវការពារសិទ្ធិនោះ ឬត្រូវអនុវត្តដោយយកចិត្តទុកដាក់ឲ្យបានត្រឹមត្រូវ ដើម្បីទប់ស្កាត់ ផ្តន្ទាទោស ស៊ើបអង្កេត និងផ្តល់សំណងចំពោះព្យសនៈកម្ម ដែលបង្កឡើងដោយរូបវន្តបុគ្គល ឬនីតិបុគ្គល និង

(គ) ត្រូវផ្តល់ប្រសិទ្ធភាពដល់សិទ្ធិនោះ ឬត្រូវចាត់វិធានការផ្សេងៗជាវិជ្ជមាន ឬជាបរិសកម្ម ដើម្បីធ្វើឲ្យសម្រេចបានដល់សិទ្ធិនោះ។

*តើសេចក្តីពន្យល់ទូទៅ គឺជាអ្វី?*

សេចក្តីពន្យល់ទូទៅ គឺជាមធ្យោបាយមួយដែលក្នុងនោះគណៈកម្មាធិការសិទ្ធិមនុស្ស (ដែលជាស្ថាប័ននៃអ្នកជំនាញឯករាជ្យ ឃ្លាំមើលការអនុវត្ត ICCPR ដោយរដ្ឋភាគី) បោះពុម្ពផ្សព្វផ្សាយនូវការបកស្រាយរបស់ខ្លួន អំពីខ្លឹមសារនៃបទបញ្ញត្តិនានារបស់ ICCPR អំពីបញ្ហាតាមវិស័យ ដើម្បីកុំឲ្យមានចម្ងល់អំពីវិសាលភាព និងអត្ថន័យនៃមាត្រានីមួយៗ។

*ខ្លឹមសារនៃសេចក្តីពន្យល់ទូទៅលេខ៣៤*

សេចក្តីពន្យល់ទូទៅលេខ៣៤ ត្រូវបានអនុម័តដោយគណៈកម្មាធិការសិទ្ធិមនុស្ស នៅខែកក្កដា ឆ្នាំ២០១១។ សេចក្តីពន្យល់នេះ ដាក់ជំនួសសេចក្តីពន្យល់ទូទៅលេខ១០ កាលពីលើកមុន។ សេចក្តីពន្យល់នេះ ផ្តល់នូវការពន្យល់បំភ្លឺអំពីបញ្ហាដូចខាងក្រោម៖

(ក) ការយល់ឃើញជាទូទៅអំពីសេរីភាពនៃគំនិត និងការបញ្ចេញមតិ

(ខ) ធាតុផ្សំនៃនិយមន័យអំពីសេរីភាពនៃគំនិត និងការបញ្ចេញមតិ

(គ) សេរីភាពនៃការបញ្ចេញមតិ និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន

(ឃ) សិទ្ធិទទួលបានព័ត៌មាន

(ង) សេរីភាពនៃការបញ្ចេញមតិ និងសិទ្ធិនយោបាយ

(ច) ការអនុវត្តមាត្រា១៩(៣) ពោលគឺ អំពីការរឹតត្បឹតដែលអាចអនុញ្ញាតឲ្យបានទៅលើសេរីភាពនៃគំនិត និងការបញ្ចេញមតិ(ជាអាទិ៍នៅពេលដែលការធ្វើយុត្តិកម្ម ត្រូវបានធ្វើឡើង អំពីសន្តិសុខជាតិ និងការរក្សាសណ្តាប់ធ្នាប់សាធារណៈ)

(ឆ) វិសាលភាពមានដែនកំណត់នៃការរឹតត្បឹត ទៅលើសេរីភាពនៃការបញ្ចេញមតិ នៅក្នុងវិស័យជាក់លាក់មួយចំនួន (ដូចជា អំឡុងពេលបោះឆ្នោត ការរិៈគន់មន្ត្រីសាធារណៈ អង្គការសារព័ត៌មាន ប្រព័ន្ធផ្សព្វផ្សាយតាមអ៊ីនធឺណេត វិជ្ជាជីវៈខាងសារព័ត៌មាន ច្បាប់ស្តីពីបរិហារកេរ្តិ៍)

(ជ) ទំនាក់ទំនងរវាងមាត្រា១៩ និងមាត្រា២០ (ស្តីពីការឃោសនាឲ្យមានសង្គ្រាម និងស្តីពីការញុះញង់ឲ្យមានការស្អប់ខ្ពើមខាងពូជសាសន៍ និងសាសនា)។

ដោយសារតែការរឹតត្បឹតដែលអាចអនុញ្ញាតឲ្យបាន ទៅលើសេរីភាពនៃគំនិត និងការបញ្ចេញមតិ គឺជាធាតុផ្សំមួយក្នុងចំណោមធាតុផ្សំទាំងឡាយដ៏ពិបាកបំផុតនៃមាត្រា១៩ គណៈកម្មាធិការសិទ្ធិមនុស្ស បានផ្តោតផ្នែកដ៏សំខាន់នៃសេចក្តីពន្យល់របស់ខ្លួនទៅលើបញ្ហានេះ។ គណៈកម្មាធិការ ព្យាយាមបំភ្លឺអំពីព្រំដែននៃមូលដ្ឋានជាធម្មានុរូបចំនួនពីរ ដែលសេរីភាពនៃគំនិត និងការបញ្ចេញមតិ អាចត្រូវបានរឹតត្បឹត ដោយសង្កត់ធ្ងន់ថា ការរឹតត្បឹតដូចនេះ ត្រូវតែស្របទៅតាមភាពចាំបាច់ និងភាពសមមាត្រដ៏តឹងរឹង ហើយថា រដ្ឋត្រូវតែបង្ហាញឲ្យបានជាក់លាក់ថា ការគំរាមកំហែងបង្កឡើងដោយការបញ្ចេញមតិនោះ តម្រូវឲ្យដាក់ការរឹតត្បឹត។ សេចក្តីពន្យល់ទូទៅនេះ ក៏រក្សាជំហរផងដែរថា រដ្ឋទាំងឡាយត្រូវតែបរិសកម្មក្នុងការបង្កើតវិធានការនានា ដែលការពារប្រឆាំងនឹងការវាយប្រហារដែលមានបំណងបំបិទមាត់ជនទាំងឡាយណា ដែលអនុវត្តសិទ្ធិសេរីភាពនៃការបញ្ចេញមតិរបស់គេ។

ជារួម សេចក្តីពន្យល់ទូទៅលេខ៣៤ គឺជាការអះអាងឡើងវិញ អំពីសារៈសំខាន់ជាស្នូលនៃសេរីភាពនៃគំនិត និងការបញ្ចេញមតិសម្រាប់សិទ្ធិមនុស្សទាំងអស់។ ហេតុដូច្នេះ សេចក្តីពន្យល់នេះ កំណត់ពីវិជ្ជមាត្រដ៏ចង្អៀត ដែលរដ្ឋអាច

រឹតត្បឹតសិទ្ធិនេះបាន។ សេរីភាពនៃការបញ្ចេញមតិ បំរើឲ្យប្រយោជន៍របស់រដ្ឋ ដោយការអនុញ្ញាតិឲ្យមានសំលេង និងថ្លែងពីការរិៈគន់ដោយសេរី ជាជាងផ្សព្វផ្សាយដោយលាក់លៀម តាមមធ្យោបាយមួយធ្វើឲ្យអន្តរាយដល់អំណាចរដ្ឋ។ រដ្ឋដែលខកខានមិនបានធានាការពារសេរីភាពនៃគំនិត និងការបញ្ចេញមតិ ក៏ប្រឈមនឹងហានិភ័យក្នុងការធ្វើឲ្យខូចខាតដល់ស្មារតីប្រកបដោយការច្នៃប្រឌិត និងដ៏មានសារៈសំខាន់របស់ប្រជាពលរដ្ឋខ្លួន។ សេរីភាពនៃការបញ្ចេញមតិមានសារៈសំខាន់ស្មើនឹងផលប្រយោជន៍របស់ប្រជាពលរដ្ឋ។ វាអនុញ្ញាតិឲ្យមានការចូលរួមខាងផ្នែកនយោបាយ និងសកម្មនិយមខាងសង្គមស៊ីវិល និងការប្រព្រឹត្តទៅរបស់រដ្ឋ វាផ្តល់នូវការជឿទុកចិត្តទៅលើការបោះឆ្នោត និងការអនុវត្តសិទ្ធិក្នុងការបោះឆ្នោតដោយសេរី ហើយវាផ្តល់ជាមូលដ្ឋានគ្រឹះមួយ ដើម្បីឲ្យប្រជាពលរដ្ឋ អាចក្រោកឈរក្នុងការការពារសិទ្ធិផ្សេងៗទាំងអស់ ដែលពួកគេត្រូវទទួលបានស្របតាមច្បាប់។

ការិយាល័យឧត្តមស្នងការ អង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា កំពុងតែបោះពុម្ពផ្សព្វផ្សាយឯកសារដ៏សំខាន់នេះ ដោយមានក្តីសង្ឃឹមថា ឯកសារនេះនឹងជាជំនួយស្មារតីដល់រាជរដ្ឋាភិបាល និងដៃគូដទៃទៀត ក្នុងកិច្ចខិតខំប្រឹងប្រែងពួកគេ ដើម្បីអនុវត្តគោលនយោបាយផ្សេងៗទាក់ទងនឹងសេរីភាពនៃគំនិត និងការបញ្ចេញមតិ ដើម្បីជាផលប្រយោជន៍សម្រាប់ប្រជាពលរដ្ឋគ្រប់រូបនៅកម្ពុជា។

ការិយាល័យឧត្តមស្នងការ<br>
អង្គការសហប្រជាជាតិ<br>
ទទួលបន្ទុកសិទ្ធិមនុស្ស<br>
ប្រចាំកម្ពុជា<br>
ខែវិច្ឆិកា ឆ្នាំ២០១២

## មាត្រា ១៩

១. ជនគ្រប់រូបមានសិទ្ធិប្រកាន់យកមតិយោបល់ដោយគ្មានការជ្រៀតជ្រែក។

២.ជនគ្រប់រូបមានសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ។ សិទ្ធិនេះត្រូវរាប់បញ្ចូលទាំងសេរីភាពស្រាវជ្រាវព័ត៌មាន ទទួល និងផ្សព្វផ្សាយព័ត៌មាន និងគំនិតសព្វបែបយ៉ាងដោយមិនគិតពីព្រំដែន ដោយផ្ទាល់មាត់ សរសេរ ឬបោះពុម្ពតាមទម្រង់សិល្បៈក្តី ឬក៏ដោយមធ្យោបាយផ្សព្វផ្សាយដទៃទៀតក្តីតាមការជ្រើសរើសរបស់ខ្លួន។

៣. ការប្រើប្រាស់សិទ្ធិដែលចែងក្នុងកថាខណ្ឌ២ នៃមាត្រានេះតម្រូវឱ្យមានករណីយកិច្ច និងការទទួលខុសត្រូវពិសេស។ ដូច្នេះ ការប្រើប្រាស់សិទ្ធិនេះអាចមានការរិតត្បិតមួយចំនួនដែលត្រូវកំណត់ដាច់ខាតដោយច្បាប់ និងដែលចាំបាច់ដើម្បី ៖

(ក) គោរពសិទ្ធិ និងកិត្តិសព្ទរបស់អ្នកដទៃ។

(ខ) ការពារសន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ សុខភាព ឬសីលធម៌សាធារណៈ។

# សេចក្តីពន្យល់ទូទៅលេខ៣៤

## មាត្រា១៩ ៖ សេរីភាពនៃគំនិត និងសេរីភាពនៃការបញ្ចេញមតិ

### កំណត់សំគាល់ទូទៅ

១. សេចក្តីពន្យល់ទូទៅនេះ ដាក់ជំនួសសេចក្តីពន្យល់ទូទៅលេខ ១០ (សម័យប្រជុំលើកទី១៩)។

២. សេរីភាពនៃគំនិត និងសេរីភាពនៃការបញ្ចេញមតិ គឺជាលក្ខខណ្ឌដែលមិនអាចកាត់ផ្តាច់បាន សំរាប់ការអភិវឌ្ឍន៍ពេញលេញរបស់មនុស្ស។[1] សេរីភាពទាំងនេះ មានសារៈសំខាន់ជាសារវ័ន្តសំរាប់សង្គមណាក៏ដោយ។ សេរីភាពទាំងនេះ បង្កើតជាមូលដ្ឋានគ្រឹះដល់គ្រប់សង្គមប្រជាធិបតេយ្យនិងសេរី។ សេរីភាពទាំងពីរនេះ មានទំនាក់ទំនងគ្នាយ៉ាងជិតដិត ដោយសេរីភាពនៃការបញ្ចេញមតិ គឺជាយានសំរាប់ការផ្លាស់ប្តូរ និងការអភិវឌ្ឍន៍នៃគំនិត។

៣. សេរីភាពនៃការបញ្ចេញមតិ គឺជាលក្ខខណ្ឌចាំចាច់មួយ សំរាប់ការធ្វើឲ្យសំរេចបាននូវគោលការណ៍នៃតម្លាភាព និងគណនេយ្យភាព ដែលមានសារៈសំខាន់ដល់ការលើកស្ទួយ និង ការការពារសិទ្ធិមនុស្ស។

[1] សូមមើលបណ្តឹងលេខ១១៧៣/២០០៣ រវាង*Benhadj និងប្រទេសអាល់ហ្សេរី,* ទស្សនៈយល់ឃើញអនុម័តកាលពីថ្ងៃទី២០ កក្កដា ២០០៧ និងបណ្តឹងលេខ៦២៨/១៩៩៥ រវាង *Park និងសាធារណៈរដ្ឋកូរ៉េ* ទស្សនៈយល់ឃើញអនុម័តកាលពីថ្ងៃទី៥ កក្កដា ១៩៩៦

៤. ក្នុងចំណោមមាត្រាដទៃទៀត ដែលមានចែងពីការធានាការពារសេរីភាពនៃគំនិត និង/ឬសេរីភាពនៃការបញ្ចេញមតិ គឺមាត្រា១៨, ១៧,២៥ និងមាត្រា២៧ ។ សេរីភាពនៃគំនិត និងសេរីភាពនៃការបញ្ចេញមតិ បង្កើតជាមូលដ្ឋានមួយសំរាប់ការទទួលបានទាំងស្រុងនូវសិទ្ធិមនុស្សដទៃទៀតកាន់តែទូលាយ។ ឧទាហរណ៍សេរីភាពនៃការបញ្ចេញមតិ គឺជាផ្នែកទាំងមូលនៃការទទួលបានសិទ្ធិមានសេរីភាពខាងការប្រជុំ និងខាងសមាគម និងការអនុវត្តសិទ្ធិបោះឆ្នោត។

៥. ដោយពិចារណាអំពីពាក្យពេចន៍ជាក់លាក់ នៃមាត្រា ១៩ កថាខ័ណ្ឌទី១ ក៏ដូចជាទំនាក់ទំនងនៃគំនិត និងយោបល់ (មាត្រា១៨) ការដាក់ខលក្ខខណ្ឌចំពោះកថាខ័ណ្ឌទី១ នឹងមិនស្របជាមួយគោលដៅ និងគោលបំណងនៃកតិកាសញ្ញានេះទេ។[2] លើសពីនេះទៅទៀត ទោះជាសេរីភាពនៃគំនិតមិនបានរាយក្នុងចំណោមសិទ្ធិទាំងឡាយដែលមិនអាចត្រូវបានធ្វើបដិបញ្ញត្តិ ដោយអនុលោមតាមបទប្បញ្ញត្តិនៃមាត្រា៤ នៃកតិកាសញ្ញានេះក៏ដោយ ក៏ត្រូវតែរំលឹកឡើងវិញថា "នៅក្នុងបញ្ញត្តិទាំងឡាយនៃកតិកាសញ្ញា ដែលមិនបានរាយក្នុងមាត្រា៤ កថាខ័ណ្ឌទី២ នៅមានធាតុផ្សំមួយចំនួន

[2] សូមមើលសេចក្តីពន្យល់ទូទៅលេខ២៤(១៩៩៤) របស់គណៈកម្មាធិការ ស្តីពីបញ្ហានានាពាក់ព័ន្ធនឹងការដាក់ខលក្ខខណ្ឌនៅពេលផ្តល់សច្ចាប័ន ឬចូលជាសមាជិកនៃកតិកាសញ្ញា ឬពិធីសារបន្ថែមនៃកតិកាសញ្ញានេះ ឬទាក់ទងនឹងការប្រកាសសេចក្តីតាមមាត្រា៤១ នៃកតិកាសញ្ញានេះ កំណត់ហេតុផ្លូវការរបស់មហាសន្និបាតអង្គការសហប្រជាជាតិ សម័យប្រជុំលើកទី១៥ សំណៅបន្ថែមលេខ ៤0 vol. I (A/50/40 (Vol. I)), ឧបសម្ព័ន្ធ V.

ទៀត ដែលតាមយោបល់របស់គណៈកម្មាធិការ មិនអាចត្រូវបានធ្វើបដិប្បញ្ញត្តិស្របច្បាប់ក្រោមមាត្រា៤″ ឡើយ។[3] សេរីភាពនៃគំនិត គឺជាធាតុផ្សំមួយ ដោយសារតែសេរីភាពនេះ មិនដែលអាចក្លាយជាការចាំបាច់ ដើម្បីធ្វើបដិបញ្ញត្តិក្នុងពេលរដ្ឋមានគ្រាអាសន្នឡើយ។[4]

**៦**. ដោយពិចារណាអំពីទំនាក់ទំនងរវាងសេរីភាពនៃការបញ្ចេញមតិជាមួយសិទ្ធិដទៃទៀតនៅក្នុងកតិកាសញ្ញានេះ ទោះជាការដាក់ខលក្ខខណ្ឌ ចំពោះធាតុផ្សំជាក់លាក់ណាមួយនៃមាត្រា ១៩ កថាខ័ណ្ឌទី២ អាចទទួលយកបានក្តី ក៏ការដាក់ខលក្ខខណ្ឌទូទៅមួយចំពោះសិទ្ធិដូចមានចែងក្នុងកថាខ័ណ្ឌទី២ នឹងមិនស្របជាមួយគោលដៅ និងគោលបំណងនៃកតិកាសញ្ញានេះទេ។[5]

**៧**. កាតព្វកិច្ចគោរពសេរីភាពនៃគំនិត និងការបញ្ចេញមតិ អនុវត្តលើគ្រប់រដ្ឋភាគី ទូទាំងផ្ទៃប្រទេស។ គ្រប់ស្ថាប័នរបស់រដ្ឋភាគី (ស្ថាប័ននីតិប្រតិបត្តិ ស្ថាប័ននីតិបញ្ញត្តិ និងតុលាការ) និងអាជ្ញាធរសាធារណៈ ឬអាជ្ញាធររដ្ឋាភិបាលដទៃទៀត ទោះជានៅថ្នាក់ណាក៏ដោយ (ថ្នាក់ជាតិ តំបន់ ឬមូលដ្ឋាន) សុទ្ធតែមានតួនាទីអនុវត្ត

[3] សូមមើលសេចក្តីពន្យល់ទូទៅលេខ២៩ (២០០១) របស់គណៈកម្មាធិការ ស្តីពីការធ្វើបដិបញ្ញត្តិក្នុងពេលរដ្ឋមានគ្រាអាសន្ន កថាខ័ណ្ឌទី១៣ កំណត់ហេតុផ្លូវការរបស់មហាសន្និបាតអង្គការសហប្រជាជាតិ សម័យប្រជុំលើកទី៥៦ សំណៅបន្ថែមលេខ៤០ vol. I (A/56/40 (Vol. I)), ឧបសម្ព័ន្ធទី VI.

[4] សេចក្តីពន្យល់ទូទៅលេខ២៩ កថាខ័ណ្ឌទី១១

[5] សេចក្តីពន្យល់ទូទៅលេខ២៤

ការទទួលខុសត្រូវរបស់រដ្ឋ។[6] ការទទួលខុសត្រូវនេះ ក៏អាចអនុវត្ត ផងដែរដោយរដ្ឋភាគី ក្រោមកាលៈទេសៈមួយចំនួន ទាក់ទងនឹង អំពើរបស់អង្គភាពពាក់កណ្តាលរដ្ឋ។[7] កាតព្វកិច្ចនេះ ក៏តម្រូវផង ដែរឲ្យរដ្ឋភាគីធានាថា បុគ្គលគ្រប់រូប ត្រូវរួចផុតពីអំពើណាមួយ របស់អង្គភាព ឬបុគ្គលឯកជន ដែលនាំឲ្យប៉ះពាល់ដល់ការទទួល បានសេរីភាពនៃគំនិត និងការបញ្ចេញមតិ ទៅតាមវិសាលភាព មួយដែលថា សិទ្ធិទាំងឡាយក្នុងកតិកាសញ្ញានេះ អាចធានាដល់ ការអនុវត្តន៍រវាងអង្គភាព ឬបុគ្គលឯកជន។[8]

៨. រដ្ឋភាគីត្រូវបានតម្រូវឲ្យធានាថា សិទ្ធិដែលមានចែងក្នុងមាត្រា ១៩ នៃកតិកាសញ្ញានេះ ត្រូវបានផ្តល់អនុភាពឱ្យនៅក្នុងច្បាប់ជាតិ របស់រដ្ឋ ក្នុងឋានៈមួយដែលស្របតាមគោលការណ៍ណែនាំ ដែល គណៈកម្មាធិការបានផ្តល់ឱ្យ នៅក្នុងសេចក្តីពន្យល់ទូទៅរបស់ខ្លួន លេខ៣១ស្តីពីចរិតលក្ខណៈនៃកាតព្វកិច្ចតាមផ្លូវច្បាប់ជាទូទៅដែល បានកំណត់ឲ្យរដ្ឋភាគីនៃកតិកាសញ្ញានេះ។ គួររំលឹកដែរថា រដ្ឋភាគី គួរផ្តល់ឲ្យគណៈកម្មាធិការ ដោយអនុលោមតាមរបាយការណ៍

[6] សូមមើលសេចក្តីពន្យល់ទូទៅលេខ៣១ (២០០៤) របស់គណៈកម្មាធិការស្តីពីចរិកលក្ខណៈនៃ កាតព្វកិច្ចផ្លូវច្បាប់ជាទូទៅរបស់រដ្ឋភាគីចំពោះកតិកាសញ្ញា កថាខ័ណ្ឌទី៤ កំណត់ហេតុផ្លូវការរបស់ មហាសន្និបាតអង្គការសហប្រជាជាតិ សម័យប្រជុំលើកទី៥៩ សំណៅបន្ថែមលេខ៤០ vol. I (A/59/40 (Vol. I)), ឧបសម្ព័ន្ធទី III

[7] សូមមើលបណ្តឹងលេខ៦១/១៩៧៩ រវាង *Hertzberg et al និងប្រទេសហ្វាំងឡង់* ទស្សនៈយល់ ឃើញអនុម័តកាលពីថ្ងៃទី០២ មេសា ១៩៨២។

[8] សេចក្តីពន្យល់ទូទៅលេខ៣១ កថាខ័ណ្ឌទី៨ សូមមើលបណ្តឹងលេខ៦៣៣/១៩៩៥ រវាង *Gauthier និងប្រទេសកាណាដា* ទស្សនៈយល់ឃើញអនុម័តកាលពីថ្ងៃទី៧ មេសា ១៩៩៩

ទាំងឡាយដែលបានដាក់ជូន ស្របតាមមាត្រា៤០ នៃកតិកាសញ្ញានេះ ជាមួយនឹងវិធានគតិយុត្តជាតិដែលពាក់ព័ន្ធការអនុវត្តន៍ផ្នែករដ្ឋបាល និងសេចក្ដីសំរេចផ្សេងៗរបស់តុលាការ ក៏ដូចជាកំរិតគោលនយោបាយពាក់ព័ន្ធ និងការអនុវត្តន៍តាមវិស័យផ្សេងៗទៀតទាក់ទងនឹងសិទ្ធិទាំងឡាយ ដែលត្រូវបានការពារដោយមាត្រា១៩ ដោយយកមកពិចារណានូវបញ្ហា ដែលបានពិភាក្សានៅក្នុងសេចក្ដីពន្យល់ទូទៅនេះ។ រដ្ឋភាគីគួរដាក់បញ្ចូលផងដែរ នូវព័ត៌មានស្ដីពីការដោះស្រាយដែលមានស្រាប់ ប្រសិនបើសិទ្ធិទាំងនោះ ត្រូវបានរំលោភបំពាន។

## សេរីភាពនៃគំនិត

៩. កថាខ័ណ្ឌទី១ នៃមាត្រា១៩ តម្រូវឲ្យមានការការពារសិទ្ធិប្រកាន់នូវគំនិតដោយគ្មានការជ្រៀតជ្រែក។ នេះគឺជាសិទ្ធិមួយដែលកតិកាសញ្ញានេះ ផ្ដល់ឲ្យដោយគ្មានអញ្ញត្រកម្ម ឬការរិតត្បិតឡើយ។ សេរីភាពនៃគំនិត លាតសន្ធឹងលើសិទ្ធិផ្លាស់ប្ដូរគំនិត នៅពេលណា និងសំរាប់ហេតុផលអ្វីក៏ដោយ តាមតែបុគ្គលម្នាក់ជ្រើសរើសដោយសេរី។ គ្មានជនណាម្នាក់ អាចត្រូវទទួលរងនូវការខូចខាតដល់សិទ្ធិណាមួយក្រោមកតិកាសញ្ញានេះទេ ដោយផ្អែកលើគំនិតជាក់ស្ដែង ដែលខ្លួនបានយល់ដឹង ឬដែលបានសន្មត់ឡើយ។ គំនិតតាមគ្រប់រូបភាពត្រូវបានការពារ រាប់ទាំងគំនិតដែលមានចរិតលក្ខណៈជានយោបាយ វិទ្យាសាស្រ្ត ប្រវត្តិសាស្រ្ត សីលធម៌ ឬ

សាសនា។ ការដាក់ជាបទព្រហ្មទណ្ឌ ចំពោះការប្រកាន់នូវគំនិតមិនស្របនឹងកថាខ័ណ្ឌទី១ នេះទេ។[9] ការយាយី ការបំភិតបំភ័យ ឬការបង្កើតឱ្យមានភាពហ្មងសៅដល់បុគ្គលណាមួយ រាប់ទាំងការចាប់ខ្លួន ការឃុំខ្លួន ការជំនុំជម្រះ ឬការដាក់ពន្ធនាគារដោយសារហេតុផលនៃគំនិត ដែលពួកគេអាចប្រកាន់យក គឺជាការរំលោភបំពានលើមាត្រា១៩ កថាខ័ណ្ឌទី១ នេះ។[10]

១០. កិច្ចខិតខំប្រឹងប្រែងតាមរូបភាពណាក៏ដោយ ដើម្បីបង្ខិតបង្ខំឲ្យប្រកាន់យក ឬមិនប្រកាន់យកគំនិតណាមួយ ត្រូវបានហាមឃាត់។[11] សេរីភាពដើម្បីសំដែងគំនិតរបស់បុគ្គលម្នាក់ក៏ចាំបាច់ត្រូវរាប់បញ្ចូល សេរីភាពមិនសំដែងគំនិតរបស់បុគ្គលនោះផងដែរ។

## សេរីភាពនៃការបញ្ចេញមតិ

១១. កថាខ័ណ្ឌទី២ តម្រូវឲ្យរដ្ឋភាគី ធានាការពារសិទ្ធិមានសេរីភាពនៃការបញ្ចេញមតិ រាប់ទាំងសិទ្ធិស្វែងរក ទទួលនិងចែករំលែកព័ត៌មាន និងគំនិតគ្រប់បែបយ៉ាងដោយគ្មានដែនកំណត់។ សិទ្ធិនេះ

---

[9] សូមមើលបណ្តឹងលេខ៥៥០/៩៣ រវាង*Faurissonនិងប្រទេសបារាំង* ទស្សនៈយល់ឃើញអនុម័តកាលពីថ្ងៃ៨ វិច្ឆិកា ១៩៩៦។

[10] សូមមើលបណ្តឹងលេខ១៥៧/១៩៨៣ រវាង*Mpaka-Nsusu និងប្រទេសហ្សាអៀ* ទស្សនៈយល់ឃើញអនុម័តកាលពីថ្ងៃទី២៦ មីនា ១៩៨៦ និងបណ្តឹងលេខ៤១៤/១៩៩០ រវាង *Mika Miha និងប្រទេសហ្គីនាអេក្វាទ័រ* ទស្សនៈយល់ឃើញអនុម័តកាលពីថ្ងៃទី៨ កក្កដា ១៩៩៤។

[11] សូមមើលបណ្តឹងលេខ៨៧៨/១៩៩៩ រវាង *Kang និងសាធារណៈរដ្ឋកូរ៉េ* ទស្សនៈយល់ឃើញអនុម័តកាលពីថ្ងៃទី១៥ កក្កដា ២០០៣។

រាប់ទាំងការសំដែង និងការទទួលយកនូវការប្រាស្រ័យទាក់ទងតាមគ្រប់រូបភាពនៃគំនិត និងយោបល់ដែលអាចបញ្ជូនបន្តទៅអ្នកដទៃទៀត ស្ថិតក្រោមបទបញ្ញត្តិក្នុងមាត្រា១៩ កថាខណ្ឌទី៣ និងមាត្រា២០។[12] សិទ្ធិនេះ រាប់ទាំងសន្ទរកថានយោបាយ[13] និងបទអត្ថាធិប្បាយអំពីកិច្ចការខ្លួនផ្ទាល់[14] និងអំពីកិច្ចការសាធារណៈ[15] ការត្រួតពិនិត្យយ៉ាងម៉ត់ចត់[16] ការពិភាក្សាអំពីសិទ្ធិមនុស្ស[17] វិជ្ជាជីវៈខាងសារព័ត៌មាន[18] ការសំដែងវប្បធម៌ និងសិល្បៈ[19] ការបង្រៀន[20] និងសន្ទរកថាសាសនា។[21] សិទ្ធិនេះ ក៏អាចរាប់បញ្ចូលទាំងការផ្សាយពាណិជ្ជកម្មផងដែរ។ វិសាលភាពនៃកថាខណ្ឌទី ២ គ្រប

---

[12] សូមមើលបណ្តឹងលេខ៣៥៩/១៩៨៩និងបណ្តឹងលេខ៣៨៥/១៩៨៩ រវាង*Ballantyne, Davidson*និង*McIntyre និងប្រទេសកាណាដា* ទស្សនៈយល់ឃើញអនុម័តកាលពីថ្ងៃទី១៨ តុលា ១៩៩០

[13] សូមមើលបណ្តឹងលេខ៤១៤/១៩៩០ រវាង *Mika Miha* និងប្រទេសហ្គីនាអេក្វាទ័រ។

[14] សូមមើលបណ្តឹងលេខ១១៨៩/២០០៣ រវាង *Fernando* និងប្រទេសស្រីលង្កា ទស្សនៈយល់ឃើញអនុម័តកាលពីថ្ងៃទី៣១ មីនា ២០០៥។

[15] សូមមើលបណ្តឹងលេខ១១៥៧/២០០៣ រវាង *Coleman* និងប្រទេសអូស្ត្រាលី ទស្សនៈយល់ឃើញអនុម័តកាលពីថ្ងៃទី១៧ កក្កដា ២០០៦។

[16] សេចក្តីសង្កេតសន្និដ្ឋានសំរាប់ប្រទេសជប៉ុន(CCPR/C/JPN/CO/5)។

[17] សូមមើលបណ្តឹងលេខ១០២២/២០០១ រវាង *Velichkin* និងប្រទេសបេឡារ៉ុស ទស្សនៈយល់ឃើញអនុម័តកាលពីថ្ងៃទី២០ តុលា ២០០៥។

[18] សូមមើលបណ្តឹងលេខ១៣៣៤/២០០៤ រវាង *Mavlonov and Sa´di* និងប្រទេសអ៊ុយបេគីស្ថាន ទស្សនៈយល់ឃើញអនុម័តកាលពីថ្ងៃទី១៩ មីនា ២០០៩។

[19] សូមមើលបណ្តឹងលេខ៩២៦/២០០០ រវាង *Shin* និងសាធារណរដ្ឋកូរ៉េ ទស្សនៈយល់ឃើញអនុម័តកាលពីថ្ងៃទី១៦ មីនា ២០០៤។

[20] សូមមើលបណ្តឹងលេខ៧៣៦/៩៧ រវាង*Ross* និងប្រទេសកាណាដា ទស្សនៈយល់ឃើញអនុម័តកាលពីថ្ងៃទី១៨ តុលា ២០០០។

[21] សូមមើលបណ្តឹងខាងលើ រវាង *Ross* និងប្រទេសកាណាដា

ដណ្តាប់ ទាំងលើការបញ្ចេញមតិ ដែលអាចចាត់ទុកថាជាពាក្យសំដីវាយប្រហារធ្ងន់ៗ[22] ទោះបីជាការសំដែងមតិបែបនេះ អាចត្រូវបានរិតត្បិត អនុលោមតាមបញ្ញត្តិនៃមាត្រា១៩ កថាខណ្ឌទី៣ និងមាត្រា២០ ក៏ដោយ។

១២. កថាខណ្ឌទី២ ការពារការសម្តែងមតិតាមគ្រប់ទម្រង់ និងមធ្យោបាយផ្សព្វផ្សាយមតិ។ ទម្រង់ទាំងនេះរាប់ទាំងភាសានិយាយសរសេរ និងភាសាសញ្ញា ហើយការសម្តែងមតិដោយមិនចេញជាសំដីបែបនេះ មានដូចជាតាមរយៈរូបភាពនិងវត្ថុសិល្បៈ។[23] មធ្យោបាយសំដែងមតិ រាប់ទាំងសៀវភៅ កាសែត[24] បទវិចារណកថា[25] ប័ណ្ណប្រកាស បដា[26] សំលៀកបំពាក់ និងឯកសារច្បាប់នានា[27] រួមទាំងគ្រប់ទម្រង់ ដទៃទៀត តាមសោតទស្សន៍ ព្រមទាំងវិធីសំដែងមតិតាមរយៈអ៊ីនធឺណែត និងអេឡិចត្រូនិកផង។

---

[22] សូមមើលបណ្តឹងខាងលើ រវាង *Ross* និងប្រទេសកាណាដា។

[23] សូមមើលបណ្តឹងលេខ៩២៦/២០០០ រវាង *Shin* និងសាធារណរដ្ឋកូរ៉េ ទស្សនៈយល់ឃើញអនុម័តកាលពីថ្ងៃទី១៦ មីនា ២០០៤។

[24] សូមមើលបណ្តឹងលេខ១៣៤១/២០០៥ រវាង*Zundel*និងប្រទេសកាណាដា ទស្សនៈយល់ឃើញអនុម័តកាលពីថ្ងៃទី២០ មីនា ២០០៧។

[25] សូមមើលបណ្តឹងលេខ១០០៩/២០០១ រវាង *Shchetoko et al* និងប្រទេសបេឡារូស ទស្សនៈយល់ឃើញអនុម័តកាលពីថ្ងៃទី១១ កក្កដា ២០០៤។

[26] សូមមើលបណ្តឹងលេខ៤១២/១៩៩០ រវាង *Kivenmaa* និងប្រទេសហ្វាំងឡង់ ទស្សនៈយល់ឃើញអនុម័តកាលពីថ្ងៃទី៣១ មីនា ១៩៩៤។

[27] សូមមើលបណ្តឹងលេខ១១៨៩/២០០៣ រវាង *Fernando* និងប្រទេសស្រីលង្កា។

## សេរីភាពនៃការបញ្ចេញមតិ និងប្រព័ន្ធសារព័ត៌មាន

១៣. សារព័ត៌មាន ឬប្រព័ន្ធផ្សព្វផ្សាយផ្សេងទៀតដែលសេរី គ្មានការត្រួតពិនិត្យនិងរិតត្បិត មានសារៈសំខាន់ក្នុងសង្គមណាក៏ដោយ ដើម្បីធានាដល់សេរីភាពនៃគំនិតនិងការសំដែងមតិ និងការទទួលបានសិទ្ធិដទៃទៀតនៃកតិកាសញ្ញានេះ។[28] សេរីភាពនេះបង្កើតជាសរសរគ្រឹះមួយក្នុងចំណោមសរសរគ្រឹះដទៃទៀត ក្នុងសង្គមប្រជាធិបតេយ្យ។ កតិកាសញ្ញានេះ ក្រសោបយកសិទ្ធិមួយ ដែលតាមរយៈនេះ ប្រព័ន្ធផ្សព្វផ្សាយ អាចទទួលបានព័ត៌មាន ដោយឈរលើមូលដ្ឋានមួយដែលព័ត៌មាននេះអាចបំពេញមុខងាររបស់វាបាន។[29] ការប្រាស្រ័យទាក់ទងដោយសេរីនៃព័ត៌មាន និងមតិយោបល់អំពីបញ្ហាសាធារណៈ និងបញ្ហានយោបាយ រវាងប្រជាពលរដ្ឋ បេក្ខជន និងតំណាងជាប់ឆ្នោត គឺជាការសំខាន់។ វាឆ្លុះបញ្ចាំងអំពីសារព័ត៌មានសេរី និងប្រព័ន្ធផ្សព្វផ្សាយផ្សេងទៀត អាចធ្វើអធិប្បាយអំពីបញ្ហាសាធារណៈ ដោយគ្មានការត្រួតពិនិត្យចាប់ទោស ឬការដាក់កំហិត និងដើម្បីផ្តល់ព័ត៌មានអំពីមតិសាធារណៈ។[30] សាធារណៈជនក៏មានសិទ្ធិដូចគ្នាផងដែរ ក្នុងការទទួលបានព័ត៌មានពីប្រព័ន្ធផ្សព្វផ្សាយទាំងនេះ។[31]

---

[28] សូមមើលបណ្តឹងលេខ១១២៨/២០០២ រវាង *Marques* និងប្រទេសអង់ហ្គោឡា ទស្សនៈយល់ឃើញអនុម័តកាលពីថ្ងៃទី២៩ មីនា ២០០៥។

[29] សូមមើលបណ្តឹងលេខ៦៣៣/៩៥ រវាង *Gauthier* និងប្រទេសកាណាដា។

[30] សូមមើលសេចក្តីពន្យល់ទូទៅលេខ២៥(១៩៩៦) របស់គណៈកម្មាធិការស្តីពីមាត្រា២៥ (ការចូលរួមក្នុងកិច្ចការសាធារណៈ និងសិទ្ធិបោះឆ្នោត) កថាខ័ណ្ឌទី២៥ កំណត់ហេតុផ្លូវការរបស់មហាសន្និបាតអង្គការសហប្រជាជាតិ សម័យប្រជុំលើកទី៥១ សំណៅបន្ថែមលេខ៤០ vol. I (A/51/40 (Vol. I)), ឧបសម្ព័ន្ធទី V

[31] សូមមើលបណ្តឹងលេខ១៣៣៤/២០០៤ រវាង *Mavlonov and Sa´di* និងប្រទេសអ៊ុយបេគីស្ថាន

១៤. ជាមធ្យោបាយមួយ ដើម្បីការពារសិទ្ធិអ្នកប្រើប្រាស់ប្រព័ន្ធព័ត៌មាន រាប់ទាំងសមាជិកនៃក្រុមនិគមជន និងជនភាគតិចខាងភាសា ក្នុងការទទួលបានព័ត៌មាន និងគំនិតយោបល់ផ្សេងៗយ៉ាងទូលំទូលាយនោះ រដ្ឋភាគីគួរយកចិត្តទុកដាក់ជាពិសេស លើកទឹកចិត្តឲ្យមានប្រព័ន្ធផ្សព្វផ្សាយផ្សេងៗ និងឯករាជ្យ។

១៥. រដ្ឋភាគី គួរគិតគូរអំពីកំរិតនៃការវិវត្តន៍ផ្នែកបច្ចេកវិទ្យាទំនាក់ទំនងនិងព័ត៌មាន ដូចជា អ៊ីនធឺណែតនិងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានអេឡិចត្រូនិកចល័ត បានផ្លាស់ប្តូរជាដំកំភូន នូវការអនុវត្តន៍ទំនាក់ទំនងគ្នាជុំវិញពិភពលោក។ បច្ចុប្បន្ននេះមានបណ្តាញសកលមួយសំរាប់ការផ្លាស់ប្តូរគំនិតយោបល់ ដែលមិនចាំបាច់ពឹងផ្អែកលើអន្តរការីប្រព័ន្ធផ្សព្វផ្សាយមហាជនតាមបែបប្រពៃណីទៀតឡើយ។ រដ្ឋភាគីគួរចាត់រាល់វិធានការចាំបាច់ដើម្បីពង្រឹងឯករាជ្យភាពនៃប្រព័ន្ធផ្សព្វផ្សាយថ្មីទាំងនេះ ហើយធានាឲ្យបុគ្គលគ្រប់រូប ទទួលបានប្រព័ន្ធទាំងនេះ។

១៦. រដ្ឋភាគី គួរធានាថា សេវាផ្សាយព័ត៌មានសាធារណៈ ដំណើរការប្រកបដោយឯករាជ្យ។[32] ដូច្នេះ រដ្ឋភាគី គួរតែធានាការពារឯករាជ្យភាព និងសេរីភាពខាងការពុម្ពផ្សាយរបស់ពួកគេ។ រដ្ឋភាគី គួរផ្តល់មូលនិធិក្នុងលក្ខណៈមួយដែលមិនធ្វើឲ្យប៉ះពាល់ដល់ឯករាជ្យភាពរបស់ពួកគេ។

[32] សេចក្តីសង្កេតសន្និដ្ឋានសំរាប់សាធារណៈរដ្ឋម៉ុលដូវ៉ា (CCPR/CO/75/MDA)។

១៧. បញ្ហាទាក់ទងនឹងប្រព័ន្ធផ្សព្វផ្សាយ ត្រូវបានពិភាក្សាថែមទៀតក្នុងផ្នែកនៃសេចក្តីពន្យល់ទូទៅនេះ ដែលលើកឡើងអំពីការរិតត្បិតលើសេរីភាពនៃការបញ្ចេញមតិ។

## សិទ្ធិទទួលបានព័ត៌មាន

១៨. មាត្រា១៩ កថាខ័ណ្ឌទី២ គ្របដណ្តប់លើសិទ្ធិទទួលបានព័ត៌មានដែលគ្រប់គ្រងដោយស្ថាប័នសាធារណៈ។ ព័ត៌មាននេះ រាប់ទាំង កំណត់ហេតុដែលគ្រប់គ្រងដោយស្ថាប័នសាធារណៈ ដោយមិនគិតពីទម្រង់ដែលព័ត៌មាននោះត្រូវរក្សាទុក ប្រភព និងកាលបរិច្ឆេទនៃការផលិតនោះឡើយ។ ស្ថាប័នសាធារណៈ គឺជាស្ថាប័នដូចបានគូសបញ្ជាក់ក្នុងកថាខ័ណ្ឌទី៧នៃសេចក្តីពន្យល់ទូទៅនេះ។ ការចាត់តាំងនៃស្ថាប័នទាំងនេះ ក៏អាចរាប់បញ្ចូលផងដែរនូវអង្គភាពដទៃទៀត នៅពេលដែលអង្គភាពទាំងនោះ បំពេញមុខងារសាធារណៈ។ ដូចបានកត់សំគាល់រួចហើយ ដោយគួរផ្សំជាមួយមាត្រា២៥នៃកតិកាសញ្ញានេះ សិទ្ធិទទួលបានព័ត៌មានរាប់ទាំងសិទ្ធិដែលប្រព័ន្ធផ្សព្វផ្សាយទទួលបានព័ត៌មានអំពីកិច្ចការសាធារណៈ[33] និងសិទ្ធិរបស់សាធារណៈជនទូទៅ ក្នុងការទទួលបានព័ត៌មានតាមប្រព័ន្ធផ្សព្វផ្សាយ។[34] ធាតុផ្សំនៃសិទ្ធិទទួលបានព័ត៌មានក៏មានចែងផងដែរ ក្នុងបញ្ញត្តិផ្សេងៗ នៃកតិកាសញ្ញានេះ។ ដូចដែលគណៈកម្មាធិការ បានសង្កេតឃើញនៅក្នុងសេចក្តីពន្យល់ទូទៅរបស់ខ្លួន

[33] សូមមើលបណ្តឹងលេខ៦៣៣/៩៥ រវាង *Gauthier* និងប្រទេសកាណាដា។

[34] សូមមើលបណ្តឹងលេខ១៣៣៤/២០០៤ រវាង *Mavlonov and Sa'di* និងប្រទេសអ៊ុយបេគីស្ថាន

លេខ១៦ពាក់ព័ន្ធនឹងមាត្រា១៧ នៃកតិកាសញ្ញានេះ បុគ្គលគ្រប់រូបគួរតែមានសិទ្ធិបញ្ជាក់ច្បាស់តាមទម្រង់មួយងាយយល់ ហើយប្រសិនជាដូច្នោះ ថាតើទិន្នន័យផ្ទាល់ខ្លួនអ្វីខ្លះដែលត្រូវបានរក្សាទុកក្នុងសំណុំឯកសារទិន្នន័យស្វ័យប្រវត្តិ និងសំរាប់គោលបំណងអ្វីខ្លះ។ បុគ្គលគ្រប់រូប គួរតែអាចបញ្ជាក់ច្បាស់ផងដែរថាតើអាជ្ញាធរសាធារណៈ ឬបុគ្គលឯកជន ឬស្ថាប័នឯកជនណាមួយ មានសិទ្ធិពិនិត្យ ឬអាចពិនិត្យសំណុំឯកសាររបស់គាត់បាន។ ប្រសិនជាសំណុំឯកសារបែបនេះ មានទិន្នន័យផ្ទាល់ខ្លួនដែលមិនត្រឹមត្រូវ ឬត្រូវបានប្រមូល ឬចាត់ឱ្យប្រើប្រាស់ផ្ទុយនឹងបញ្ញត្តិនៃច្បាប់នេះ បុគ្គលគ្រប់រូប គួរតែមានសិទ្ធិឲ្យគេធ្វើការកែតម្រូវសំណុំឯកសាររបស់ខ្លួនឡើងវិញ។ អនុលោមតាមមាត្រា១០ នៃកតិកាសញ្ញានេះ ជនជាប់ឃុំ មិនត្រូវបាត់បង់សិទ្ធិពិនិត្យមើលឯកសារពេទ្យរបស់ខ្លួនឡើយ។[35] នៅក្នុងសេចក្តីពន្យល់ទូទៅលេខ៣២ លើមាត្រា១៤ នៃកតិកាសញ្ញានេះ គណៈកម្មាធិការ បានកំណត់ពីការមានសិទ្ធិផ្សេងៗ ក្នុងការទទួលបានព័ត៌មានដែលគ្រប់គ្រងដោយជនត្រូវចោទពីបទព្រហ្មទណ្ឌ។[36] អនុលោមតាមបញ្ញតិនៃមាត្រា២ បុគ្គលគ្រប់រូប គួរមានសិទ្ធិទទួលបានព័ត៌មាន ទាក់ទងនឹងសិទ្ធិជាទូទៅ

---

[35] សូមមើលបណ្តឹងលេខ៧២៦/១៩៩៦ រវាង *Zheludkov និងប្រទេសអ៊ុយក្រែន* ទស្សនៈយល់ឃើញអនុម័តកាលពីថ្ងៃទី២៩ តុលា ២០០២។

[36] សូមមើលសេចក្តីពន្យល់ទូទៅលេខ៣២(២០០៧) របស់គណៈកម្មាធិការស្តីពីសិទ្ធិស្មើភាពគ្នានៅចំពោះមុខច្បាប់ និងសាលាជម្រះក្តី និងសិទ្ធិទទួលបានសវនាការត្រឹមត្រូវមួយ កថាខ័ណ្ឌទី៣៣ កំណត់ហេតុផ្លូវការរបស់មហាសន្និបាតអង្គការសហប្រជាជាតិ សម័យប្រជុំលើកទី៦២ សំណៅបន្ថែម លេខ៤០ vol. I (A/62/40 (Vol. I)), ឧបសម្ព័ន្ធទី VI

របស់ខ្លួនក្នុងកតិកាសញ្ញានេះ។[37] តាមមាត្រា២៧ ការធ្វើសេចក្តីសំរេចរបស់រដ្ឋភាគី ដែលអាចជួយសម្រួលជាដំកំភួនដល់របៀបរបបរស់នៅ និងវប្បធម៌របស់ក្រុមជនភាគតិចណាមួយគួរតែត្រូវធ្វើឡើងក្នុងដំណើរការមួយ ដែលមានការពិគ្រោះយោបល់ និងការចែករំលែកព័ត៌មានជាមួយសហគមន៍ដែលទទួលរងផលប៉ះពាល់។[38]

**១៩.** ដើម្បីធ្វើឱ្យមានប្រសិទ្ធភាពដល់សិទ្ធិទទួលបានព័ត៌មាន រដ្ឋភាគីគួររៀបចំឲ្យបានសកម្មជាងមុន ក្នុងការទុកដាក់ព័ត៌មាន ទៅក្នុងប្រព័ន្ធផ្សព្វផ្សាយសាធារណៈ នូវព័ត៌មានរបស់រដ្ឋាភិបាលដែលទាក់ទងនឹងផលប្រយោជន៍សាធារណៈ។ រដ្ឋភាគី គួរប្រឹងប្រែងគ្រប់បែបយ៉ាង ដើម្បីធានាឱ្យមានការទទួលបានដោយងាយស្រួលឆាប់រហ័ស មានប្រសិទ្ធភាព និងជាក់ស្តែង នូវព័ត៌មានដូចនេះ។ រដ្ឋភាគីគួរអនុម័តផងដែរ នូវនីតិវិធីចាំបាច់ ដែលតាមរយៈនេះ គេអាចទទួលបានព័ត៌មាន ជាអាទិ៍ តាមរយៈច្បាប់ស្តីពីសេរីភាពខាងព័ត៌មាន។[39] នីតិវិធីនេះ គួរចែងអំពីចំណាត់ការឱ្យបានទាន់ពេលវេលា លើសំណើសុំព័ត៌មាន យោងតាមវិធានច្បាស់លាស់ដែលស្របនឹងកតិកាសញ្ញានេះ។ កំរៃសំរាប់ការស្នើសុំព័ត៌មាននេះ មិនគួរបង្កជាឧបសគ្គមិនសមហេតុផល ដល់លទ្ធភាពទទួលបានព័ត៌

[37] សូមមើលសេចក្តីពន្យល់ទូទៅលេខ៣១

[38] សូមមើលបណ្តឹងលេខ១៤៥៧/២០០៦ រវាង *Poma និងប្រទេសប៉េរូ* ទស្សនៈយល់ឃើញអនុម័តកាលពីថ្ងៃទី២៧ មីនា ២០០៩។

[39] សូមមើលសេចក្តីសង្កេតសន្និដ្ឋានសំរាប់ប្រទេសអាហ្សែបៃហ្សាន(CCPR/C/79/Add.38(1994))

មានឡើយ។ អាជ្ញាធរគួរតែផ្តល់ហេតុផលចំពោះការបដិសេធណាមួយពីការផ្តល់សិទ្ធិទទួលបានព័ត៌មាន។ ដំណោះស្រាយផ្សេងៗគួរតែត្រូវដាក់ឱ្យអនុវត្តសម្រាប់ការប្តឹងតវ៉ាអំពីការបដិសេធមិនផ្តល់សិទ្ធិទទួលបានព័ត៌មាន ក៏ដូចជាករណីមិនមានការឆ្លើយតបនឹងការស្នើសុំនេះ។

## សេរីភាពនៃការបញ្ចេញមតិ និងសិទ្ធិនយោបាយ

២០. នៅក្នុងសេចក្តីពន្យល់ទូទៅលេខ២៥ ស្តីពីការចូលរួមក្នុងកិច្ចការសាធារណៈ និងសិទ្ធិបោះឆ្នោត គណៈកម្មាធិការបានបរិយាយអំពីសារៈសំខាន់នៃសេរីភាពនៃការបញ្ចេញមតិ សំរាប់ការប្រព្រឹត្តទៅនៃកិច្ចការសាធារណៈ និងការប្រើប្រាស់សិទ្ធិបោះឆ្នោតប្រកបដោយប្រសិទ្ធភាព។ការប្រាស្រ័យទាក់ទងគ្នាដោយសេរីនៃព័ត៌មាន និងមតិយោបល់អំពីបញ្ហាសាធារណៈ និងនយោបាយ រវាងប្រជាពលរដ្ឋ បេក្ខជន និងតំណាងជាប់ឆ្នោតគឺជាការសំខាន់។ នេះសឲ្យឃើញថា សារព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយដទៃទៀតដែលមានលក្ខណៈសេរី អាចធ្វើអត្ថាធិប្បាយអំពីបញ្ហាសាធារណៈ និងប្រាប់ឲ្យដឹងអំពីមតិសាធារណៈ ដោយគ្មានការត្រួតពិនិត្យឬការរិតត្បិត។[40] រដ្ឋភាគីទាំងឡាយត្រូវចាប់អារម្មណ៍លើការណែនាំ នៅក្នុងសេចក្តីពន្យល់ទូទៅលេខ២៥ ស្តីពីការលើកស្ទួយនិងការការពារសេរីភាពនៃការបញ្ចេញមតិ ក្នុងបរិបទនេះ។

[40] សូមមើលសេចក្តីពន្យល់ទូទៅលេខ២៥ ស្តីពីមាត្រា២៥នៃកតិកាសញ្ញា កថាខ័ណ្ឌទី២៥

## ការអនុវត្តមាត្រា១៩(៣)

២១. កថាខ័ណ្ឌទី៣ ចែងយ៉ាងច្បាស់ថាការប្រើប្រាស់សិទ្ធិមានសេរីភាពនៃការបញ្ចេញមតិ អនុវត្តទន្ទឹមនឹងភារកិច្ច និងការទទួលខុសត្រូវជាក់លាក់។ សំរាប់ហេតុផលនេះ ចំណុចពីរនៃការរិតត្បិតសិទ្ធិនេះ ត្រូវបានអនុញ្ញាតដែលអាចទាក់ទងនឹង ឬមួយការគោរពសិទ្ធិ ឬកេរ្តិ៍ឈ្មោះរបស់អ្នកដទៃ ឬមួយទៀត ការការពារសន្តិសុខជាតិឬសណ្តាប់ធ្នាប់សាធារណៈ សីលធម៌ឬសុខភាពសាធារណៈ។ ទោះជាយ៉ាងណាក៏ដោយ កាលណារដ្ឋភាគីដាក់ការរិតត្បិតទៅលើការប្រើប្រាស់សេរីភាពនៃការបញ្ចេញមតិ ការរិតត្បិតទាំងនេះ មិនអាចធ្វើឲ្យអន្តរាយដល់សិទ្ធិនេះឡើយ។ គណៈកម្មាធិការរំលឹកថា ទំនាក់ទំនងរវាងសិទ្ធិ និងការរិតត្បិត និងទំនាក់ទំនងរវាងបទដ្ឋាន និងអញ្ញត្រកម្ម មិនត្រូវធ្វើឲ្យផ្ទុយគ្នាឡើយ។[41] គណៈកម្មាធិការ ក៏បានរំលឹកផងដែរអំពីបទប្បញ្ញត្តិនៃមាត្រា៥ កថាខ័ណ្ឌទី១នៃកតិកាសញ្ញានេះ ដែលមានន័យថា "គ្មានបទប្បញ្ញត្តិណាមួយ នៅក្នុងកតិកាសញ្ញានេះ អាចត្រូវបានបកស្រាយថាជាការតម្រូវឱ្យរដ្ឋណាមួយ ក្រុមណាមួយ ឬបុគ្គលណាម្នាក់ មានសិទ្ធិចូលរួមធ្វើសកម្មភាព ឬប្រព្រឹត្តអំពើអ្វីមួយ ដែលសំដៅដល់ការបំផ្លិចបំផ្លាញណាមួយនៃសិទ្ធិ និងសេរីភាពដែលត្រូវបានទទួលស្គាល់នៅក្នុងកតិកាសញ្ញានេះ ឬសំដៅដល់ការរិតត្បិត ដែលមានវិសាលភាពធំជាងកម្រិតដែលមានចែងនៅក្នុងកតិកាសញ្ញានេះឡើយ។

[41] សូមមើលសេចក្តីពន្យល់ទូទៅលេខ២៧ របស់គណៈកម្មាធិការស្តីពីមាត្រា១២ កំណត់ហេតុផ្លូវការរបស់មហាសន្និបាតអង្គការសហប្រជាជាតិ សម័យប្រជុំលើកទី៥៥ សំណៅបន្ថែមលេខ៤០ vol. I (A/55/40 (Vol. I)), ឧបសម្ព័ន្ធទី VI ផ្នែក-ក

**២២**. កថាខ័ណ្ឌទី៣ចែងអំពីលក្ខខណ្ឌជាក់លាក់មួយចំនួន ហើយមានតែតាមលក្ខខណ្ឌទាំងនេះទេ ទើបការរិតត្បិតអាចធ្វើទៅបាន៖ ការរិតត្បិតនេះ ត្រូវតែមាន "ចែងដោយច្បាប់" ការរិតត្បិតនេះទៀតសោធ អាចធ្វើទៅបាន ដោយឈរលើហេតុផលមួយ ក្នុងចំណោមហេតុផលទាំងឡាយ ដែលមានចែងនៅក្នុងអនុកថាខ័ណ្ឌ (ក) និង (ខ)នៃកថាខ័ណ្ឌទី៣ ហើយត្រូវតែស្របនឹងការសាកល្បងដ៏តឹងរឹងអំពីភាពចាំបាច់ និងភាពសមាមាត្រ។[42] ការរិតត្បិតមិនត្រូវបានអនុញ្ញាតទេ បើហេតុផលទាំងឡាយដែលផ្ដល់ឱ្យ មិនមានចែងជាក់លាក់ដូចក្នុងកថាខ័ណ្ឌទី៣ នោះ ទោះបីជាហេតុផលនោះអាចធ្វើយុត្តិកម្មដល់ការរិតត្បិតសិទ្ធិដទៃទៀត ដែលត្រូវបានការពារក្នុងកតិកាសញ្ញានេះក៏ដោយ។ ការរិតត្បិត ត្រូវតែយកមកអនុវត្តបានតែសំរាប់គោលបំណងទាំងឡាយដែលត្រូវបានបញ្ញត្តិ ហើយត្រូវតែទាក់ទងដោយផ្ទាល់នឹងសេចក្ដីត្រូវការជាក់លាក់ ដែលត្រូវបានសំអាងលើ។[43]

**២៣**. រដ្ឋភាគី គួរដាក់ចេញនូវវិធានការមានប្រសិទ្ធភាព ដើម្បីការពារប្រឆាំងនឹងការវាយប្រហារ ដែលមានគោលដៅបំបិទមាត់អ្នកទាំងឡាយដែលប្រើប្រាស់សិទ្ធិសេរីភាពនៃការបញ្ចេញមតិ។ កថា

[42] សូមមើលបណ្ដឹងលេខ១០២២/២០០១ រវាង *Velichkin* និងប្រទេសបេឡារ៉ុស ទស្សនៈយល់ឃើញអនុម័តកាលពីថ្ងៃទី២០ តុលា ២០០៥។

[43] សូមមើលសេចក្ដីពន្យល់ទូទៅលេខ២២ របស់គណៈកម្មាធិការ កំណត់ហេតុផ្លូវការរបស់មហាសន្និបាតអង្គការសហប្រជាជាតិ សម័យប្រជុំលើកទី៤៨ សំណៅបន្ថែមលេខ៤០ (A/48/40), ឧបសម្ព័ន្ធទី VI

ខ័ណ្ឌទី៣ អាចមិនដែលត្រូវគេសំអាងថាជាយុត្តិកម្ម ដើម្បីឃ្លុំមាត់ការតស៊ូមតិណាមួយនៃលិទ្ធិប្រជាធិបតេយ្យពហុបក្ស គោលការណ៍ប្រជាធិបតេយ្យនិងសិទ្ធិមនុស្សឡើយ។[44] ទោះស្ថិតក្នុងករណីណាក៏ដោយ គេមិនអាចវាយប្រហារលើបុគ្គលណាមួយ ដោយសារតែបុគ្គលនោះ ប្រើប្រាស់សេរីភាពនៃគំនិត ឬការបញ្ចេញមតិរបស់ខ្លួនឡើយ រាប់ទាំងតាមទម្រង់នៃការវាយប្រហារ ដូចជា ការចាប់ខ្លួនតាមទំនើងចិត្ត ការធ្វើទារុណកម្ម ការគំរាមកំហែងដល់អាយុជីវិត និងការគំរាមសំលាប់ជាដើម ត្រូវតែស្របតាមមាត្រា១៩។[45] ជារឿយៗ អ្នកសារព័ត៌មានតែងតែជាកម្មវត្ថុនៃការគំរាមកំហែង ការបំភិតបំភ័យ និងការវាយប្រហារបែបនេះ ព្រោះតែសកម្មភាពរបស់ពួកគេ។[46] ដូចគ្នានេះដែរ បុគ្គលទាំងឡាយដែលចូលរួមក្នុងការប្រមូល និងការវិភាគព័ត៌មានស្តីពីស្ថានភាពសិទ្ធិមនុស្ស និងដែលបោះពុម្ពផ្សាយរបាយការណ៍ ពាក់ព័ន្ធនឹងសិទ្ធិមនុស្ស រាប់ទាំងចៅក្រម និងមេធាវី។[47] ការវាយប្រហារទាំងនេះ គួរតែត្រូវបានធ្វើ

[44] សូមមើលបណ្តឹងលេខ៤៥៨/៩១ រវាង *Mukong* និងប្រទេសកាំមីរូន ទស្សនៈយល់ឃើញអនុម័តកាលពីថ្ងៃទី២១ កក្កដា ១៩៩៤។

[45] សូមមើលបណ្តឹងលេខ១៣៥៣/២០០៥ រវាង *Njaru* និងប្រទេសកាំមីរូន ទស្សនៈយល់ឃើញអនុម័តកាលពីថ្ងៃទី១៩ មីនា ២០០៧។

[46] ជាឧទាហរណ៍ សូមមើលសេចក្តីសង្កេតសន្និដ្ឋានសំរាប់ប្រទេសអាល់ហ្សេរី (CCPR/C/DZA/CO/3) សេចក្តីសង្កេតសន្និដ្ឋានសំរាប់ប្រទេសកូស្តារីកា(CCPR/C/CRI/CO/5) និងសេចក្តីសង្កេតសន្និដ្ឋានសំរាប់ប្រទេសស៊ូដង់ (CCPR/C/SDN/CO/3)

[47] សូមមើលបណ្តឹងលេខ១៣៥៣/២០០៥ រវាង *Njaru* និងប្រទេសកាំមីរូន សេចក្តីសង្កេតសន្និដ្ឋានសំរាប់ប្រទេសនីការ៉ាហ្គ័រ (CCPR/C/NIC/CO/3) សេចក្តីសង្កេតសន្និដ្ឋាន សំរាប់ប្រទេសទុយនេស៊ី (CCPR/C/TUN/CO/5) សេចក្តីសង្កេតសន្និដ្ឋានសំរាប់សាធារណៈរដ្ឋអារ៉ាប់ស៊ីរី(CCPR/CO/84/SYR) និងសេចក្តីសង្កេតសន្និដ្ឋានសំរាប់ប្រទេសកូឡុំប៊ី (CCPR/CO/80/COL)

ការស៊ើបអង្កេតឲ្យបានហ្មត់ចត់ ទាន់ពេលវេលា ហើយជនល្មើសត្រូវបានផ្តន្ទាទោសតាមច្បាប់[48] ហើយជនរងគ្រោះក្នុងករណីឃាតកម្ម តំណាងជនរងគ្រោះត្រូវទទួលបានការដោះស្រាយតាមទម្រង់សមរម្យ។[49]

២៤. ការរិតត្បិត ត្រូវតែមានចែងដោយច្បាប់។ ច្បាប់អាចរាប់ទាំងច្បាប់ស្តីពីបុព្វសិទ្ធិសភា[50] និង ច្បាប់ស្តីពីការប្រមាថតុលាការ។[51] ដោយសារតែការរិតត្បិតណាមួយ លើសេរីភាពនៃការបញ្ចេញមតិ បង្កើតជាការកាត់បន្ថយធ្ងន់ធ្ងរមួយលើសិទ្ធិមនុស្ស វាមិនស្របនឹងកតិកាសញ្ញានេះទេ ចំពោះការរិតត្បិតណាមួយ ដែលមានចែងក្នុងច្បាប់ប្រពៃណី សាសនា ឬច្បាប់ទំនៀមទំលាប់ដទៃទៀត។[52]

២៥. សំរាប់គោលបំណងនៃកថាខ័ណ្ឌទី៣ បទដ្ឋានមួយដែលត្រូវបានចាត់ទុកថាជា"ច្បាប់"ត្រូវតែបានបង្កើតឡើងឲ្យមានភាពច្បាស់លាស់គ្រប់គ្រាន់ ដើម្បីឲ្យបុគ្គលម្នាក់ៗ អាចបញ្ញត្តិពីការប្រព្រឹត្តរបស់ខ្លួនទៅតាមនោះ[53] ហើយត្រូវតែធ្វើឱ្យសាធារណៈជនអាច

---

[48] ដូចខាងលើ និងសូមមើលសេចក្តីសង្កេតសន្និដ្ឋានសំរាប់ប្រទេសហ្សកហ្ស៊ី (CCPR/C/GEO/CO/3)

[49] សូមមើលសេចក្តីសង្កេតសន្និដ្ឋានសំរាប់ប្រទេសហ្គុយយ៉ាណា (CCPR/C/79/Add.121)

[50] សូមមើលបណ្តឹងលេខ៦៣៣/៩៥ រវាង *Gauthier* និងប្រទេសកាណាដា។

[51] សូមមើលបណ្តឹងលេខ១៣៧៣/២០០៥ រវាង *Dissanayake* និងប្រទេសស្រីលង្កា ទស្សនៈយល់ឃើញអនុម័តកាលពីថ្ងៃទី២២ កក្កដា ២០០៨។

[52] សូមមើលសេចក្តីពន្យល់ទូទៅលេខ៣២

[53] សូមមើលបណ្តឹងលេខ៥៧៨/១៩៩៤ រវាង *de Groot* និងប្រទេសហូឡង់ ទស្សនៈយល់ឃើញអនុម័តកាលពីថ្ងៃទី១៤ កក្កដា ១៩៩៥។

ប្រើប្រាស់បាន។ ច្បាប់អាចមិនផ្តល់ឆន្ទានុសិទ្ធិ ដោយសេរីដល់ការវិតត្បិតសេរីភាពនៃការបញ្ចេញមតិ លើជនជាប់ចោទ ក្នុងទោសប្រហារជីវិតឡើយ។[54] ច្បាប់ត្រូវតែផ្តល់ការណែនាំគ្រប់គ្រាន់ដល់ជនជាប់ចោទក្នុងទោសប្រហារជីវិត ដើម្បីឲ្យពួកគេដឹងច្បាស់ថាការបញ្ចេញមតិបែបណាដែលត្រូវបានវិតត្បិតយ៉ាងត្រឹមត្រូវ ហើយការបញ្ចេញមតិបែបណា ដែលត្រូវបានវិតត្បិតមិនត្រឹមត្រូវ។

២៦. ច្បាប់ដែលវិតត្បិតសិទ្ធិនានាដូចបានរៀបរាប់ក្នុងមាត្រា១៩ កថាខ័ណ្ឌទី២ រាប់ទាំងច្បាប់ដែលបានបញ្ជាក់ក្នុងកថាខ័ណ្ឌទី២៤ ខាងលើ មិនត្រឹមតែត្រូវស្របតាមលក្ខខណ្ឌតម្រូវដ៏តឹងរឹងនៃមាត្រា ១៩ កថាខណ្ឌទី៣ នៃកតិកាសញ្ញានេះប៉ុណ្ណោះទេ ប៉ុន្តែច្បាប់នេះក៏ត្រូវតែស្របជាមួយបទប្បញ្ញត្តិ គោលដៅ និងគោលបំណងនៃកតិកាសញ្ញានេះផងដែរ។[55] ច្បាប់ទាំងនេះមិនត្រូវរំលោភបំពានលើបញ្ញត្តិមិនរើសអើង នៃកតិកាសញ្ញានេះឡើយ។ ច្បាប់ទាំងនេះមិនត្រូវចែងពីទោសទណ្ឌ ដែលមិនស្របតាមកតិកាសញ្ញានេះឡើយ ជាអាទិ៍ ទណ្ឌកម្មលើរូបរាងកាយជាដើម។[56]

---

54 សូមមើលសេចក្តីពន្យល់ទូទៅលេខ២៧

55 សូមមើលបណ្តឹងលេខ៤៨៨/១៩៩២ រវាង *Toonen* និងប្រទេសអូស្ត្រាលី ទស្សនៈយល់ឃើញអនុម័តកាលពីថ្ងៃទី៣០ មីនា ១៩៩៤។

56 សូមមើលសេចក្តីពន្យល់ទូទៅលេខ២០ របស់គណៈកម្មាធិការ កំណត់ហេតុផ្លូវការរបស់មហាសន្និបាតអង្គការសហប្រជាជាតិ សម័យប្រជុំលើកទី៤៧ សំណៅបន្ថែមលេខ៤០ (A/47/40), ឧបសម្ព័ន្ធទី VI ផ្នែកក

២៧. រដ្ឋភាគី ត្រូវបង្ហាញពីមូលដ្ឋានច្បាប់សំរាប់ការរិតត្បិតណាមួយលើសេរីភាពនៃការបញ្ចេញមតិ។[57] ទាក់ទងនឹងរដ្ឋភាគីដោយឡែកមួយ ប្រសិនបើគណៈកម្មាធិការ ត្រូវតែពិចារណាថាតើការរិតត្បិតដោយឡែកនោះ មានកំណត់ដោយច្បាប់ឬទេ រដ្ឋភាគីនោះគួរផ្តល់សេចក្តីពន្យល់លំអិតអំពីច្បាប់ និងវិធានការដែលស្ថិតក្នុងវិសាលភាពនៃច្បាប់នោះ។[58]

២៨. ហេតុផលធម្មានុរូបទីមួយសំរាប់ការរិតត្បិតសិទ្ធិ ដូចមានចែងក្នុងកថាខ័ណ្ឌទី៣ គឺការគោរពសិទ្ធិ ឬកិត្តិសព្ទរបស់អ្នកដទៃ។ ពាក្យ "សិទ្ធិ" រាប់មានសិទ្ធិមនុស្សដូចបានទទួលស្គាល់ក្នុងកតិកាសញ្ញានេះ និងទទួលស្គាល់ទូទៅជាងនេះទៅទៀត នៅក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិ។ ឧទាហរណ៍ ការរិតត្បិតសេរីភាពនៃការបញ្ចេញមតិ អាចធ្វើជាធម្មានុរូបបាន ដើម្បីការពារសិទ្ធិបោះឆ្នោតក្រោមមាត្រា២៥ ក៏ដូចជាសិទ្ធិទាំងឡាយក្រោមមាត្រា១៧ (សូមមើលកថាខ័ណ្ឌ៣៧ខាងក្រោម)។[59] ការរិតត្បិតបែបនេះ ត្រូវតែធ្វើឡើងដោយប្រុងប្រយ័ត្នៈទន្ទឹមនឹងការរិតត្បិតនេះអាចត្រូវអនុញ្ញាតិដើម្បីការពារអ្នកបោះឆ្នោត កុំឲ្យបញ្ចេញមតិតាមទម្រង់ណាដែល

---

[57] សូមមើលបណ្តឹងលេខ១៥៥៣/២០០៧ រវាង *Korneenko et al* និងប្រទេសបេឡារូស ទស្សនៈយល់ឃើញអនុម័តកាលពីថ្ងៃទី៣១ តុលា ២០០៦។

[58] សូមមើលបណ្តឹងលេខ១៣២/១៩៨២ រវាង *Jaona* និងប្រទេសម៉ាដាហ្គាស្កា ទស្សនៈយល់ឃើញអនុម័តកាលពីថ្ងៃទី១ មេសា ១៩៨៥។

[59] សូមមើលបណ្តឹងលេខ៩២៧/២០០០ រវាង *Svetik* និងប្រទេសបេឡារូស ទស្សនៈយល់ឃើញអនុម័តកាលពីថ្ងៃទី៨ កក្កដា ២០០៤។

បង្កឲ្យមានការបំភិតបំភ័យ ឬការបង្ខិតបង្ខំ ការរិតត្បិតបែបនេះមិនត្រូវរារាំងដល់ការជជែកដេញដោលគ្នាខាងនយោបាយ ឧទាហរណ៍ដូចជាការអំពាវនាវឲ្យធ្វើពហិកាពីការបោះឆ្នោតដែលមិនចាំបាច់។[60] ពាក្យ "អ្នកដទៃ" សំដៅដល់បុគ្គលផ្សេងទៀត ជាឯកត្តបុគ្គលក្តី ជាសមាជិកសហគមន៍ក្តី។[61] ដូច្នេះ ជាតួយ៉ាង ពាក្យនេះសំដៅដល់សមាជិកសហគមន៍ម្នាក់ៗដែលកំណត់ន័យដោយជំនឿសាសនា[62] ឬជាតិពន្ធុរបស់ខ្លួន។[63]

**២៩.** ហេតុផលធម្មានុរូបទីពីរគឺការការពារសន្តិសុខជាតិឬសណ្តាប់ធ្នាប់សាធារណៈ សីលធម៌ ឬសុខភាពសាធារណៈ។

**៣០.** រដ្ឋភាគីត្រូវយកចិត្តទុកដាក់បំផុត ដើម្បីធានាថា ច្បាប់ស្តីពីទោសក្បត់ជាតិ[64] និងបទប្បញ្ញត្តិស្រដៀងគ្នា ទាក់ទងនឹងសន្តិសុខជាតិ ទោះជាត្រូវអធិប្បាយថាជាការសម្ងាត់ផ្លូវការ ឬច្បាប់ស្តីពីការញុះញុងឱ្យបះបោរ ឬច្បាប់ផ្សេងពីនេះ ត្រូវបានតាក់តែងឡើង និងអនុវត្តក្នុងលក្ខណៈមួយ ស្របតាមលក្ខខណ្ឌតម្រូវដ៏តឹងរឹងនៃកថា

---

[60] ដូចខាងលើ

[61] សូមមើលបណ្តឹងលេខ៧៣៦/៩៧ រវាង *Ross* និងប្រទេសកាណាដា ទស្សនៈយល់ឃើញអនុម័តកាលពីថ្ងៃទី១៨ តុលា ២០០០។

[62] សូមមើលបណ្តឹងលេខ៥៥០/៩៣ រវាង *Faurisson* និងប្រទេសបារាំង សេចក្តីសង្កេតសន្និដ្ឋានសំរាប់ប្រទេសអូទ្រីស (CCPR/C/AUT/CO/4)

[63] សេចក្តីសង្កេតសន្និដ្ឋានសំរាប់ប្រទេសស្លូវ៉ាគី (CCPR/CO/78/SVK); សេចក្តីសង្កេតសន្និដ្ឋានសំរាប់ប្រទេសអ៊ីស្រាអែល (CCPR/CO/78/ISR)

[64] សេចក្តីសង្កេតសន្និដ្ឋានសំរាប់កោះហុងកុង (CCPR/C/HKG/CO/2)

ខណ្ឌទី៣។ ឧទាហរណ៍ វាមិនស្របគ្នានឹងកថាខណ្ឌទី៣ នេះទេ ក្នុងការបង្កើតច្បាប់បែបនេះ ដើម្បីគាបសង្កត់ឬដកហូតការផ្តល់ព័ត៌មានជាសាធារណៈ អំពីផលប្រយោជន៍សាធារណៈស្របច្បាប់ ដែលមិនប៉ះពាល់ដល់សន្តិសុខជាតិ ឬដើម្បីផ្តន្ទាទោសអ្នកសារព័ត៌មាន អ្នកស្រាវជ្រាវ សកម្មជនបរិស្ថាន អ្នកការពារសិទ្ធិមនុស្ស ឬអ្នកដទៃផ្សេងទៀត ដោយសារតែបានផ្សព្វផ្សាយពត៌មានបែបនេះ។[65] ម្យ៉ាងវិញទៀត ជាទូទៅវាមិនសមស្របក្នុងការបញ្ចូលទៅក្នុងច្បាប់នេះទេ នូវប្រភេទព័ត៌មានទាំងឡាយ ដែលទាក់ទងនឹងវិស័យពាណិជ្ជកម្ម ធនាគារ និងការរីកចំរើនផ្នែកវិទ្យាសាស្ត្រនោះ។[66] គណៈកម្មាធិការបានរកឃើញក្នុងករណីមួយថា ការរិតត្បិតទៅលើការចេញសេចក្តីថ្លែងការណ៍មួយ គាំទ្រដល់វិវាទការងារ រាប់ទាំងការកោះប្រជុំឱ្យមានកូដកម្មជាតិមួយ មិនត្រូវបានអនុញ្ញាត ដោយផ្អែកលើហេតុផលសន្តិសុខជាតិ។[67]

**៣១**. ឈរលើមូលដ្ឋាននៃការរក្សាសណ្តាប់ធ្នាប់សាធារណៈ ជាឧទាហរណ៍ អាចត្រូវអនុញ្ញាតក្នុងករណីមួយចំនួន ដើម្បីធ្វើនិយ័តកម្មពីការធ្វើសន្ទរកថា នៅកន្លែងសាធារណៈជាក់លាក់មួយ។[68] ការប្រមាថដល់ដំណើររឿងក្តីរបស់តុលាការទាក់ទងនឹងការសំដែង

---

[65] សេចក្តីសង្កេតសន្និដ្ឋានសំរាប់សហព័ន្ធរុស្ស៊ី (CCPR/CO/79/RUS)

[66] សេចក្តីសង្កេតសន្និដ្ឋានសំរាប់ប្រទេសអ៊ុយបេគីស្ថាន (CCPR/CO/71/UZB)

[67] សូមមើលបណ្តឹងលេខ៥១៨/១៩៩២ រវាង *Sohn* និងសាធារណៈរដ្ឋកូរ៉េ ទស្សនៈយល់ឃើញអនុម័តកាលពីថ្ងៃទី១៨ មីនា ១៩៩៤។

[68] សូមមើលបណ្តឹងលេខ១១៥៧/២០០៣ រវាង *Coleman* និងប្រទេសអូស្ត្រាលី។

មតិតាមទម្រង់ណាមួយ អាចត្រូវបានសាកល្បងលើហេតុផលសណ្ដាប់ធ្នាប់សាធារណៈ។ ដើម្បីអនុវត្តតាមកថាខ័ណ្ឌទី៣ ដំណើរការបែបនេះ និងការដាក់ទោសទណ្ឌ ត្រូវតែបង្ហាញពីភាពចាំបាច់ក្នុងការអនុវត្តអំណាចតុលាការ ក្នុងការរក្សាដំណើររឿងក្ដីឲ្យបានរៀបរយ។[69] ដំណើរការបែបនេះ មិនគួរត្រូវបានប្រើប្រាស់ ទោះតាមវិធីណាក៏ដោយ ដើម្បីរិតត្បិតការអនុវត្តជាធម្មានុរូបនៃសិទ្ធិការពារនោះឡើយ។

**៣២.** នៅក្នុងសេចក្ដីពន្យល់ទូទៅលេខ២២ គណៈកម្មាធិការបានសង្កេតថា "ទស្សនៈខាងសីលធម៌បានមកពីប្រពៃណីជាច្រើន មានជាអាទិ៍ សង្គម ទស្សនៈវិជ្ជា និងសាសនា ដូច្នេះការរិតត្បិតសំរាប់គោលបំណងនៃការការពារសីលធម៌ ត្រូវតែផ្អែកលើគោលការណ៍ផ្សេងៗ ដែលមិនមែនកើតចេញពីប្រពៃណីទាំងស្រុងតែមួយមុខនោះទេ"។ ការរិតត្បិតណាមួយដូចនេះត្រូវតែបានយល់តាមស្មារតីនៃសកលភាព អំពីសិទ្ធិមនុស្ស និងគោលការណ៍មិនរើសអើង។

**៣៣.** ការរិតត្បិតត្រូវតែមានភាព "ចាំបាច់" សំរាប់គោលបំណងជាធម្មានុរូប។ ដូច្នេះ ឧទាហរណ៍ បំរាមផ្សាយពាណិជ្ជកម្មតាមភាសាមួយ ដោយមានគោលដៅការពារភាសារបស់សហគមន៍ជាក់លាក់មួយ គឺរំលោភលើការសាកល្បងនៃភាពចាំបាច់ ប្រសិនជាការការពារនេះ អាចសំរេចបានតាមវិធីមួយផ្សេងទៀត ដែលមិនរិតត្បិត

[69] សូមមើលបណ្ដឹងលេខ១៣៧៣/២០០៥ រវាង *Dissanayake* និងប្រទេសស្រីលង្កា។

ដល់សេរីភាពនៃការសំដែងមតិ។[70] ម្យ៉ាងវិញទៀត គណៈកម្មាធិការបានពិចារណាថា រដ្ឋភាគីមួយបានគោរពតាមការសាកល្បងនៃភាពចាំបាច់ នៅពេលដែលរដ្ឋនោះបានផ្ទេរគ្រូបង្រៀនមួយរូបដែលបានបោះពុម្ពផ្សាយសម្ភារៈសិក្សា ដែលបង្ហាញពីអរិភាពចំពោះសហគមន៍សាសនាមួយ ទៅកាន់មុខតំណែងមួយទៀតដែលមិនបង្រៀន ដើម្បីការពារសិទ្ធិ និងសេរីភាពរបស់កុមារដែលកាន់ជំនឿសាសនានោះ នៅសាលារៀនក្នុងស្រុកមួយ។[71]

៣៤. ការរិតត្បិត មិនត្រូវមានវិសាលភាពធំធេងពេកឡើយ។ នៅក្នុងសេចក្ដីពន្យល់ទូទៅលេខ២៧ គណៈកម្មាធិការបានសង្កេតថា "វិធានការរិតត្បិត ត្រូវតែស្របតាមគោលការណ៍នៃភាពសមាមាត្រ។ វិធានការទាំងនេះត្រូវតែសមស្រប ដើម្បីសម្រេចបាននូវមុខងារការពាររបស់ខ្លួន។ វិធានការទាំងនេះត្រូវតែជាឧបករណ៍ដែលមានការបំពានតិចតួចបំផុត ក្នុងចំណោមវិធានការរិតត្បិតទាំងឡាយ ដែលអាចសំរេចបាននូវមុខងារការពាររបស់ខ្លួន។ វិធានការរិតត្បិត ត្រូវតែសមាមាត្រនឹងផលប្រយោជន៍ដែលត្រូវការពារ។ គោលការណ៍នៃភាពសមាមាត្រត្រូវតែទទួលបានការគោរព មិនត្រឹមតែក្នុងច្បាប់ដែលកំណត់ពីការរិតត្បិតប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងត្រូវទទួលបាន

---

[70] សូមមើលបណ្ដឹងលេខ៣៥៩/១៩៨៩ និងបណ្ដឹងលេខ៣៨៥/១៩៨៩ រវាង *Ballantyne, Davidson និង McIntyre និងប្រទេសកាណាដា។*

[71] សូមមើលបណ្ដឹងលេខ៧៣៦/៩៧ រវាង *Ross* និងប្រទេសកាណាដា ទស្សនៈយល់ឃើញអនុម័តកាលពីថ្ងៃទី១៨ តុលា ២០០០។

ការគោរពដោយអាជ្ញាធររដ្ឋបាល និងអាជ្ញាធរ តុលាការក្នុងការអនុវត្តច្បាប់នេះ។[72] គោលការណ៍នៃភាពសមាមាត្រ ក៏ត្រូវពិចារណាផងដែរអំពីទម្រង់ នៃការបញ្ចេញមតិពីបញ្ហាអ្វីមួយ ក៏ដូចជាមធ្យោបាយនៃការផ្សព្វផ្សាយព័ត៌មានរបស់ខ្លួន។ ឧទាហរណ៍ កតិកាសញ្ញានេះ បានផ្តល់តម្លៃយ៉ាងខ្ពស់ជាពិសេស ដល់ការបញ្ចេញមតិដោយចំហក្នុង កាលៈទេសៈនៃការជជែកដេញដោលជាសាធារណៈនៅក្នុងសង្គមប្រជាធិបតេយ្យ ទាក់ទងនឹងឥស្សរជនក្នុងជួរនយោបាយ និងក្នុងមុខងារសាធារណៈ។[73]

**៣៥.** នៅពេលដែលរដ្ឋភាគីមួយសំអាងហេតុផលស្របច្បាប់សំរាប់ការរិតត្បិតសេរីភាពនៃការបញ្ចេញមតិ រដ្ឋនោះត្រូវតែបង្ហាញពីរបៀបមួយជាក់លាក់ និងមួយៗដាច់ដោយឡែក អំពីចរិតលក្ខណៈច្បាស់លាស់នៃការគំរាមកំហែង ព្រមទាំងភាពចាំបាច់ និងភាពសមាមាត្រនៃវិធានការជាក់លាក់ណាមួយ ដែលបានចាត់ឡើងជាពិសេស ដោយបង្កើតនូវទំនាក់ទំនងដោយផ្ទាល់ និងជាបន្ទាន់រវាងការបញ្ចេញមតិ និងការគំរាមកំហែង។[74]

---

[72] សូមមើលសេចក្តីពន្យល់ទូទៅលេខ២៧ កថាខ័ណ្ឌទី១៤។
សូមមើលផងដែរបណ្តឹងលេខ១១២៨/២០០២ រវាង *Marques* និងប្រទេសអង់ហ្គោឡា និង
បណ្តឹងលេខ១១៥៧/២០០៣ រវាង *Coleman* និងប្រទេសអូស្ត្រាលី។

[73] សូមមើលបណ្តឹងលេខ១១៨០/២០០៣ រវាង *Bodrozic* និងប្រទេសសែបប៊ី និងម៉ុងតេណេហ្គ្រូ ទស្សនៈយល់ឃើញអនុម័តកាលពីថ្ងៃទី៣១ តុលា ២០០៥។

[74] សូមមើលបណ្តឹងលេខ៩២៦/២០០០ រវាង *Shin* និងសាធារណៈរដ្ឋកូរ៉េ

៣៦. គណៈកម្មាធិការ រក្សាសិទ្ធិរបស់ខ្លួន ក្នុងការវាយតម្លៃថាតើក្នុងស្ថានភាពជាក់លាក់មួយ អាចមានកាលៈទេសៈដែលនាំឲ្យការរិតត្បិតសេរីភាពនៃការបញ្ចេញមតិមានភាពចាំបាច់ឬទេ។[75] ដូច្នេះ គណៈកម្មាធិការរំលឹកថា វិសាលភាពនៃសេរីភាពនេះ មិនត្រូវបានធ្វើការវាយតម្លៃ ដោយយោងទៅលើ "គំរិតនៃការពេញចិត្ត"[76] នោះទេ ហើយដើម្បីឲ្យគណៈកម្មាធិការបំពេញមុខងារនេះបាន រដ្ឋភាគីក្នុងករណីជាក់លាក់មួយ ត្រូវបង្ហាញឲ្យបានច្បាស់លាស់អំពីចរិតលក្ខណៈជាក់លាក់ នៃការគំរាមកំហែង ដល់ហេតុផលណាមួយដែលបានរៀបរាប់ក្នុងកថាខ័ណ្ឌទី៣ ដែលបាននាំឲ្យខ្លួន ត្រូវតែរិតត្បិតសេរីភាពនៃការបញ្ចេញមតិ។[77]

---

[75] សូមមើលបណ្ដឹងលេខ៥១៨/១៩៩២ រវាង *Sohn* និងសាធារណៈរដ្ឋកូរ៉េ

[76] សូមមើលបណ្ដឹងលេខ៥១១/១៩៩២ រវាង *Ilmari Länsman et al* និងប្រទេសហ្វាំងឡង់ ទស្សនៈយល់ឃើញអនុម័តកាលពីថ្ងៃទី១៤ តុលា ១៩៩៣

[77] សូមមើលបណ្ដឹងលេខ៥១៨/១៩៩២ រវាង *Sohn* និងសាធារណៈរដ្ឋកូរ៉េ និងបណ្ដឹងលេខ៩២៦/២០០០ រវាង *Shin* និងសាធារណៈរដ្ឋកូរ៉េ

## វិសាលភាពមានកំរិតនៃការរិតត្បិតលើសេរីភាពនៃការបញ្ចេញមតិ ក្នុងវិស័យជាក់លាក់មួយចំនួន

**៣៧.** ក្នុងចំណោមការរិតត្បិត លើការថ្លែងសន្ទរកថានយោបាយ ដែលជាបុព្វហេតុធ្វើឱ្យគណៈកម្មាធិការ មានកង្វល់នោះ គឺបំរាមស្វែងរកសំលេងគាំទ្រតាមផ្ទះ[78] ការរិតត្បិតលើចំនួន និងប្រភេទនៃអត្ថបទជាលាយលក្ខណ៍អក្សរ ដែលអាចត្រូវបានចែកចាយនៅក្នុងអំឡុងពេលយុទ្ធនាការបោះឆ្នោត[79] ការរារាំងលទ្ធភាពប្រើប្រាស់ប្រភពផ្សេងៗ នៅក្នុងអំឡុងពេលបោះឆ្នោត រាប់ទាំងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានជាតិ និងអន្តរជាតិ ពីបទអត្ថាធិប្បាយនយោបាយ[80] និងការកំរិតលទ្ធភាពរបស់អ្នកនយោបាយ និងគណបក្សប្រឆាំង ក្នុងការប្រើប្រាស់កាណាល់នៃប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន។[81] រាល់ការរិតត្បិត គួរតែធ្វើស្របតាមកថាខ័ណ្ឌទី៣។ ទោះជាយ៉ាងណាក៏ដោយ វាអាចមានភាពស្របច្បាប់សំរាប់រដ្ឋភាគី រិតត្បិតការស្ទង់មតិនយោបាយ ដែលធ្វើនៅមុនពេលនៃការបោះឆ្នោតដើម្បីរក្សាសុចរិតភាពនៃដំណើរការបោះឆ្នោត។[82]

---

[78] សេចក្តីសង្កេតសន្និដ្ឋានសំរាប់ប្រទេសជប៉ុន(CCPR/C/JPN/CO/5)។

[79] ដូចខាងលើ

[80] សេចក្តីសង្កេតសន្និដ្ឋានសំរាប់ប្រទេសទុយនេស៊ី (CCPR/C/TUN/CO/5)។

[81] សេចក្តីសង្កេតសន្និដ្ឋានសំរាប់ប្រទេសតូហ្គោ(CCPR/CO/76/TGO) និងសេចក្តីសង្កេតសន្និដ្ឋានសំរាប់ប្រទេសមុលដូវ៉ា(CCPR/CO/75/MDA)។

[82] សូមមើលបណ្តឹងលេខ៩៦៨/២០០១ រវាង *Kim* និងសាធារណៈរដ្ឋកូរ៉េ ទស្សនៈយល់ឃើញអនុម័តកាលពីថ្ងៃទី១៤ មីនា ១៩៩៦។

**៣៨.** ដូចបានកត់សំគាល់ពីខាងដើមក្នុងកថាខ័ណ្ឌទី១៣ និងទី២០ ទាក់ទងនឹងខ្លឹមសារនៃសន្ទរកថានយោបាយ គណៈកម្មាធិការបានសង្កេតឃើញថាក្នុងឱកាសនៃការជជែកដេញដោយជាសាធារណៈអំពីឥស្សរជនសាធារណៈក្នុងវិស័យនយោបាយ និងស្ថាប័នសាធារណៈ កតិកាសញ្ញានេះ បានឲ្យតម្លៃខ្ពស់ជាពិសេស ទៅលើការបញ្ចេញមតិដោយសេរី។[83] ដូច្នេះ ការពិតតែមួយគត់គឺថាទម្រង់នៃការបញ្ចេញមតិ ត្រូវបានគេចាត់ទុកជាការជេប្រមាថដល់ឥស្សរជនសាធារណៈមួយនោះ គឺមិនគ្រប់គ្រាន់ទេ ក្នុងការធ្វើយុត្តិកម្មសំរាប់ការដាក់ទោសទណ្ឌ សូម្បីតែឥស្សរជនសាធារណៈអាចទទួលបានប្រយោជន៍ផងដែរ ពីបទប្បញ្ញត្តិនៃកតិកាសញ្ញានេះក៏ដោយ។[84] លើសពីនេះទៅទៀត ឥស្សរជនសាធារណៈទាំងអស់ រួមទាំងឥស្សរជនទាំងឡាយដែលប្រើប្រាស់អំណាចនយោបាយខ្ពស់បំផុតដូចជាប្រមុខរដ្ឋ និងប្រមុខរដ្ឋាភិបាលជាដើម ត្រូវតែជាកម្មវត្ថុជាធម្មានុរូបនៃការរិះគន់ និងការប្រឆាំងផ្នែកនយោបាយ។[85] អាស្រ័យហេតុនេះ គណៈកម្មាធិការ សំដែងការព្រួយបារម្ភអំពីច្បាប់នានាស្តីពីបញ្ហាបែបនេះ ដូចជាការមិនគោរពព្រះចេស្តា[86] *ការប្រមាថ*

[83] សូមមើលបណ្តឹងលេខ១១៨០/២០០៣ រវាង *Bodrozic* និងប្រទេសសែបប៊ី និងម៉ុងតេណេហ្គ្រូ ទស្សនៈយល់ឃើញអនុម័តកាលពីថ្ងៃទី៣១ តុលា ២០០៥។

[84] ដូចខាងលើ

[85] សូមមើលបណ្តឹងលេខ១១២៨/២០០២ រវាង *Marques* និងប្រទេសអង់ហ្គោឡា

[86] សូមមើលបណ្តឹងលេខ៤២២-៤២៤/១៩៩០ រវាង *Aduayom et al.* និងប្រទេសតូហ្គូ ទស្សនៈយល់ឃើញអនុម័តកាលពីថ្ងៃទី៣០ មិថុនា ១៩៩៤។

*តុលាការ*[87] ការមិនគោរពអាជ្ញាធរ[88] ការមិនគោរពទង់ជាតិ និងនិមិត្តសញ្ញាជាតិ ការបរិហារកេរ្តិ៍ប្រមុខរដ្ឋ[89] និងការការពារកិត្តិយសមន្ត្រីសាធារណៈ[90] ហើយច្បាប់ទាំងនេះ មិនត្រូវចែងពីការដាក់ទោសទណ្ឌធ្ងន់ធ្ងរថែមទៀត ដោយគ្រាន់តែផ្អែកលើអត្តសញ្ញាណរបស់បុគ្គល ដែលអាចត្រូវបានចោទសួរនោះឡើយ។ រដ្ឋភាគី មិនគួរហាមប្រាមការរិះគន់ស្ថាប័នផ្សេងៗ ដូចជាស្ថានប័នរដ្ឋបាល ឬស្ថាប័នយោធាជាដើម។[91]

**៣៩.** រដ្ឋភាគីគួរធានាថា ក្របខ័ណ្ឌច្បាប់ និងរដ្ឋបាលសំរាប់ការធ្វើនិយតកម្មពីប្រព័ន្ធផ្សព្វផ្សាយព័ត៌មានមហាជន ត្រូវស្របតាមបទប្បញ្ញត្តិនៃកថាខ័ណ្ឌ៣។[92] ប្រព័ន្ធនិយតកម្មគួរយកមកពិចារណាពីភាពខុសប្លែកគ្នារវាងវិស័យបោះពុម្ព និងចាក់ផ្សាយ និងប្រព័ន្ធអ៊ីនធឺណែត ទន្ទឹមនឹងការកត់សំគាល់ផងដែរ អំពីរបៀបដែលប្រព័ន្ធផ្សព្វផ្សាយព័ត៌មាននានាប្រមូលផ្តុំគ្នាមកតែមួយ ពោលគឺអាចរកបានព័ត៌មានទាំងអស់ តាមប្រព័ន្ធអ៊ីនធឺណែត។ ការបដិសេធមិនអនុញ្ញាតឲ្យមានការបោះពុម្ពផ្សាយសារព័ត៌មាន និងប្រព័ន្ធបោះ

[87] សូមមើលសេចក្តីសង្កេតសន្និដ្ឋានសំរាប់សាធារណៈរដ្ឋដូមីនិកកាំង (CCPR/CO/71/DOM)

[88] សូមមើលសេចក្តីសង្កេតសន្និដ្ឋានសំរាប់ប្រទេសហុងឌុយរ៉ាស់ (CCPR/C/HND/CO/1)

[89] សូមមើលសេចក្តីសង្កេតសន្និដ្ឋានសំរាប់ប្រទេសហ្សំប៊ី (CCPR/ZMB/CO/3) វក្យខ័ណ្ឌទី២៥

[90] សូមមើលសេចក្តីសង្កេតសន្និដ្ឋានសំរាប់ប្រទេសកូស្តារីកា(CCPR/C/CRI/CO/3)វក្យខ័ណ្ឌទី១១

[91] ដូចខាងលើ និងសូមមើលសេចក្តីសង្កេតសន្និដ្ឋានសំរាប់ប្រទេសទុយនេស៊ី (CCPR/C/TUN/CO/5) វក្យខ័ណ្ឌទី៩១

[92] សូមមើលសេចក្តីសង្កេតសន្និដ្ឋានសំរាប់ប្រទេសវៀតណាម (CCPR/CO/75/VNM) កថាខ័ណ្ឌទី១៨ និងសេចក្តីសង្កេតសន្និដ្ឋានសំរាប់ប្រទេសឡេសូតូ(CCPR/CO/79/Add.106)កថាខ័ណ្ឌទី២៣

ពុម្ពផ្សាយព័ត៌មាន ក្រៅពីកាលៈទេសៈជាក់លាក់នៃការអនុវត្តតាមកថាខ័ណ្ឌទី៣ គឺមិនស្របនឹងមាត្រា១៩ នេះទេ។ កាលៈទេសៈដូចនេះ មិនអាចរាប់ជាការហាមប្រាមមួយលើការបោះពុម្ពផ្សាយជាក់លាក់ណាមួយឡើយ ប្រសិនបើមិនមានខ្លឹមសារជាក់លាក់ដែលមិនធ្ងន់ល្មម អាចត្រូវបានហាមប្រាមជាធម្មានុរូប ក្រោមកថាខ័ណ្ឌទី៣។ រដ្ឋភាគី ត្រូវជៀសវាងការដាក់លក្ខខណ្ឌ សំរាប់ការចេញអាជ្ញាប័ណ្ណ ដែលមានលក្ខណៈស្មុគ្រស្មាញ និងមានតម្លៃខ្ពស់ទៅលើប្រព័ន្ធព័ត៌មានចាក់ផ្សាយ រាប់ទាំងស្ថានីយ៍ព័ត៌មានពាណិជ្ជកម្ម និងស្ថានីយ៍ព័ត៌មានសហគមន៍ផងដែរ។[93] លក្ខណៈវិនិច្ឆ័យសំរាប់អនុវត្តលក្ខខណ្ឌនេះ និងតម្លៃអាជ្ញាប័ណ្ណនេះគួរតែសមហេតុផល និងសត្យានុម័ត[94] ច្បាស់លាស់[95] តម្លាភាព[96] មិនរើសអើង និងប្រសិនបើមិនដូច្នេះទេ ត្រូវស្របតាមកតិកាសញ្ញានេះ។[97] របបចេញអាជ្ញាប័ណ្ណ សំរាប់ការផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយព័ត៌មានដែលកម្លាំងផ្សាយមានកំរិត ដូចជា សេវាសោតទស្សន៍លើដី និងតាមផ្កាយរណប គួរត្រូវបានផ្តល់ការបែងចែកប្រកបដោយសមធម៌នូវលទ្ធភាពប្រើប្រាស់ និងរលកធាតុអាកាស រវាងប្រព័ន្ធផ្សាយព័ត៌មានសាធារណៈ ពាណិជ្ជកម្ម និងសហគមន៍។ គណៈកម្មាធិការ

---

[93] សូមមើលសេចក្តីសង្កេតសន្និដ្ឋានសំរាប់ប្រទេសហ្គាំប៊ី (CCPR/CO/75/GMB)

[94] សូមមើលសេចក្តីសង្កេតសន្និដ្ឋានសំរាប់ប្រទេសលីបង់(CCPR/CO/79/Add.78)វក្យខ័ណ្ឌទី២៥

[95] សូមមើលសេចក្តីសង្កេតសន្និដ្ឋានសំរាប់ប្រទេសគុយវ៉ែត (CCPR/CO/69/KWT) និង សេចក្តីសង្កេតសន្និដ្ឋានសំរាប់ប្រទេសអ៊ុយក្រែន (CCPR/CO/73/UKR)

[96] សូមមើលសេចក្តីសង្កេតសន្និដ្ឋានសំរាប់ប្រទេសគៀកជីស្ថាន (CCPR/CO/69/KGZ)

[97] សូមមើលសេចក្តីសង្កេតសន្និដ្ឋានសំរាប់ប្រទេសអ៊ុយក្រែន (CCPR/CO/73/UKR)

ផ្តល់អនុសាសន៍ថា រដ្ឋភាគីដែលមិនទាន់បានធ្វើដូច្នេះ គួរបង្កើតឲ្យមានអាជ្ញាធរសាធារណៈ និងឯករាជ្យមួយ សំរាប់ទទួលបន្ទុកការចេញអាជ្ញាប័ណ្ណផ្សាយព័ត៌មាន ដែលមានសមត្ថកិច្ចពិនិត្យពាក្យសុំផ្សាយ និងផ្តល់អាជ្ញាប័ណ្ណ។[98]

៤០. គណៈកម្មាធិការបញ្ជាក់ជាថ្មីអំពីសេចក្តីសង្កេតរបស់ខ្លួននៅក្នុងសេចក្តីពន្យល់ទូទៅលេខ១០ ថា "ដោយសារតែវឌ្ឍនភាពនៃប្រព័ន្ធផ្សព្វផ្សាយព័ត៌មានមហាជនសម័យថ្មី ទើបមានការចាំបាច់ចាត់វិធានការមានប្រសិទ្ធភាព ដើម្បីបង្ការត្រួតត្រាបែបនេះលើប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ថាអាចជ្រៀតជ្រែកដល់សិទ្ធិបុគ្គលគ្រប់រូបចំពោះសេរីភាពនៃការសំដែងមតិ"។ រដ្ឋមិនគួរមានការត្រួតត្រាផ្តាច់មុខលើប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងគួរលើកកំពស់ពហុភាពនៃប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន។[99] អាស្រ័យហេតុនេះ រដ្ឋភាគីគួរចាត់វិធានការសមស្រប អនុលោមតាមកតិកាសញ្ញានេះ ដើម្បីបង្ការការត្រួតត្រាមិនត្រឹមត្រូវលើប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ឬការប្រមូលផ្តុំដោយក្រុមប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ដែលគ្រប់គ្រងដោយឯកជនក្នុងស្ថានភាពផ្តាច់មុខ ដែលអាចប៉ះពាល់ដល់ភាពចម្រុះនៃប្រភព និងទស្សនៈយល់ឃើញ។

---

[98] សូមមើលសេចក្តីសង្កេតសន្និដ្ឋានសំរាប់ប្រទេសលីបង់ (CCPR/CO/79/Add.78)

[99] សូមមើលសេចក្តីសង្កេតសន្និដ្ឋានសំរាប់ប្រទេសហ្គុយយ៉ាណា (CCPR/CO/79/Add.121) វក្យខ័ណ្ឌទី១៩ សេចក្តីសង្កេតសន្និដ្ឋានសំរាប់សហព័ន្ធរុស្ស៊ី (CCPR/CO/79/RUS) សេចក្តីសង្កេតសន្និដ្ឋានសំរាប់ប្រទេសវៀតណាម (CCPR/CO/75/VNM) សេចក្តីសង្កេតសន្និដ្ឋានសំរាប់ប្រទេសអ៊ីតាលី (CCPR/C/79/Add.37)

៤១. ត្រូវយកចិត្តទុកដាក់ធានាថា ប្រព័ន្ធផ្តល់ហិរញ្ញប្បទានរបស់រដ្ឋាភិបាលដល់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងការដាក់សេចក្តីប្រកាសផ្សាយរបស់រដ្ឋាភិបាល[100] មិនត្រូវបានប្រើប្រាស់ឲ្យមានឥទ្ធិពលរារាំងដល់សេរីភាពនៃការសំដែងមតិឡើយ។[101] លើសពីនេះទៅទៀត ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានឯកជន មិនត្រូវដាក់ឲ្យស្ថិតក្នុងស្ថានភាពមួយចាញ់ប្រៀប បើធៀបទៅនឹងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានរបស់រដ្ឋ នៅក្នុងបញ្ហានេះឡើយ ដោយសារតែលទ្ធភាពទទួលបានមធ្យោបាយនៃការផ្សព្វផ្សាយ/ការចែកចាយព័ត៌មាន និងលទ្ធភាពទទួលបានព័ត៌មាន។[102]

៤២.ការដាក់ទោសទណ្ឌចំពោះប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន អ្នកបោះពុម្ពផ្សាយ ឬអ្នកសារព័ត៌មាន ដោយគ្រាន់តែរិះគន់រដ្ឋាភិបាល ឬប្រព័ន្ធសង្គមនយោបាយមួយ ដែលគាំទ្រដោយរដ្ឋាភិបាល[103] មិនដែលត្រូវចាត់ទុកថាជាការរឹតត្បិតមួយចាំបាច់ លើសេរីភាពនៃការសំដែងមតិឡើយ។

៤៣.ការរឹតត្បិតណាមួយលើប្រតិបត្តិការគេហទំព័រ បណ្តាញសង្គមប្លុជ ឬប្រតិបត្តិការដទៃផ្សេងទៀតដែលផ្អែកលើប្រព័ន្ធអ៊ីនធឺណែត

---

[100] សូមមើលសេចក្តីសង្កេតសន្និដ្ឋានសំរាប់ប្រទេសឡេសូតូ(CCPR/CO/79/Add.106) កថាខ័ណ្ឌទី២២

[101] សូមមើលសេចក្តីសង្កេតសន្និដ្ឋានសំរាប់ប្រទេសអ៊ុយក្រែន (CCPR/CO/73/UKR)

[102] សូមមើលសេចក្តីសង្កេតសន្និដ្ឋានសំរាប់ប្រទេសស្រីលង្កា (CCPR/CO/79/LKA) និងសេចក្តីសង្កេតសន្និដ្ឋានសំរាប់ប្រទេសតូហ្គោ (CCPR/CO/76/TGO) កថាខ័ណ្ឌទី១៧

[103] សូមមើលសេចក្តីសង្កេតសន្និដ្ឋានសំរាប់ប្រទេសប៉េរូ (CCPR/CO/70/PER)

អេឡិចត្រូនិក ឬប្រព័ន្ធផ្សព្វផ្សាយព័ត៌មានផ្សេងទៀត រាប់ទាំងប្រព័ន្ធគាំទ្រដល់ទំនាក់ទំនងទាំងនេះ ដូចជាអ្នកផ្តល់សេវាកម្មអ៊ីនធឺណែត ឬម៉ាស៊ីនស្វែងរក អាចអនុញ្ញាតបានតែក្នុងវិសាលភាពមួយដែលស្របតាមកថាខ័ណ្ឌទី៣។ ការរិតត្បិតដែលអាចអនុញ្ញាតបានជាទូទៅគួរតែលើខ្លឹមសារជាក់លាក់ បំរាមតាមប្រភេទពីប្រតិបត្តិការនៃប្រព័ន្ធ និងផ្នែកមួយចំនួន គឺមិនស្របតាមកថាខ័ណ្ឌទី៣ឡើយ។ វាមិនស្របនឹងកថាខ័ណ្ឌទី៣ ផងដែរ ចំពោះការហាមលើផ្នែក ឬប្រព័ន្ធផ្សព្វផ្សាយព័ត៌មានណាមួយ ពីការចុះផ្សាយអត្ថបទដោយសារគ្រាន់តែអត្ថបទនេះ អាចមានការរិះគន់រដ្ឋាភិបាល ឬប្រព័ន្ធសង្គមនយោបាយមួយដែលរដ្ឋាភិបាលគាំទ្រ។[104]

៤៤. វិជ្ជាជីវៈសារព័ត៌មានគឺជាមុខងារមួយដែលត្រូវបានចែករំលែកពីតួអង្គជាច្រើនយ៉ាងទូលាយ រាប់ទាំងអ្នករាយការណ៍និងអ្នកវិភាគវិជ្ជាជីវៈធ្វើការពេញម៉ោង ព្រមទាំងអ្នកមានប្លុជផ្ទាល់ខ្លួន និងអ្នកឯទៀតដែលធ្វើការក្នុងរូបភាពស្វ័យបោះពុម្ពផ្សាយអត្ថបទ នៅលើប្រព័ន្ធអ៊ីនធឺណែត ឬប្រព័ន្ធដទៃផ្សេងទៀត ហើយប្រព័ន្ធចុះបញ្ជីឬផ្តល់អាជ្ញាប័ណ្ណជាទូទៅរបស់រដ្ឋដល់អ្នកសារព័ត៌មាន មិនស្របនឹងកថាខ័ណ្ឌទី៣ នេះទេ។ គម្រោងទទួលស្គាល់ជាផ្លូវការមានកំណត់អាចអនុញ្ញាតបាន តែក្នុងករណីចាំបាច់ប៉ុណ្ណោះ ដើម្បីផ្តល់ឲ្យអ្នកសារព័ត៌មាននូវបុព្វសិទ្ធិចេញ-ចូលទីកន្លែង និង/ឬ ព្រឹត្តិការណ៍មួយ

[104] សូមមើលសេចក្តីសង្កេតសន្និដ្ឋានសំរាប់សាធារណៈរដ្ឋអារ៉ាប់សេរី (CCPR/CO/84/SYR)

ចំនួន។ គម្រោងដូចនេះ គួរត្រូវបានអនុវត្តក្នុងលក្ខណៈមួយដោយគ្មានការរើសអើង និងស្របតាមមាត្រា១៩ និងបទបញ្ញត្តិដទៃទៀតនៃកតិកាសញ្ញានេះ ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យជាក់លាក់ និងដោយពិចារណាថា វិជ្ជាជីវៈសារព័ត៌មាន គឺជាមុខងារមួយដែលត្រូវបានចែករំលែកពីតួអង្គជាច្រើនយ៉ាងទូលាយ។

៤៥. តាមធម្មតា វាមិនស្របនឹងកថាខ័ណ្ឌទី៣ ទេ ក្នុងការរិតត្បិតសេរីភាពរបស់អ្នកសារព័ត៌មាន និងអ្នកដទៃទៀតដែលព្យាយាមអនុវត្តសេរីភាពនៃការបញ្ចេញមតិរបស់ខ្លួន (ដូចជា អ្នកដែលមានបំណងធ្វើដំណើរទៅចូលរួមក្នុងការប្រជុំផ្សេងៗ ទាក់ទងនឹងសិទ្ធិមនុស្ស)[105] ការធ្វើដំណើរចេញក្រៅរដ្ឋភាគី ការរិតត្បិតអ្នកសារព័ត៌មានបរទេសចំពោះការចូលក្នុងរដ្ឋភាគី ដល់អ្នកដែលមកពីប្រទេសជាក់លាក់មួយចំនួន[106] ឬរិតត្បិតសេរីភាពក្នុងការដើរហើររបស់អ្នកសារព័ត៌មាន និងអ្នកស៊ើបអង្កេតសិទ្ធិមនុស្សនៅក្នុងរដ្ឋភាគី (រាប់ទាំង ទីកន្លែងដែលរងផលប៉ះពាល់ពីជំលោះ កន្លែងមានគ្រោះធម្មជាតិនិងកន្លែងដែលគេអះអាងថាមានការរំលោភបំពានសិទ្ធិមនុស្ស)។ រដ្ឋភាគីគួរទទួលស្គាល់ និងគោរពធាតុផ្សំនៃសិទ្ធិមានសេរីភាពនៃការបញ្ចេញមតិ ដែលក្រសោបនូវលើបុព្វសិទ្ធិមានដែនកំណត់របស់អ្នកសារព័ត៌មាន ក្នុងការមិនបញ្ចេញឲ្យដឹងពីប្រភពព័ត៌មាន។[107]

[105] សូមមើលសេចក្តីសង្កេតសន្និដ្ឋានសំរាប់ប្រទេសអ៊ុយបេគីស្ថាន (CCPR/CO/83/UZB) និងសេចក្តីសង្កេតសន្និដ្ឋានសំរាប់ប្រទេសម៉ូរ៉ុកកូ (CCPR/CO/82/MAR)

[106] សូមមើលសេចក្តីសង្កេតសន្និដ្ឋានសាធារណៈរដ្ឋប្រជាធិបតេយ្យកូរ៉េ (CCPR/CO/72/PRK)

[107] សូមមើលសេចក្តីសង្កេតសន្និដ្ឋានសំរាប់ប្រទេសគុយវ៉ែត (CCPR/CO/69/KWT)

៤៦. រដ្ឋភាគីគួរធានាថា វិធានការប្រឆាំងភេរវកម្មត្រូវស្របនឹងកថាខ័ណ្ឌ៣។ បទល្មើសបែបនេះ ដូចជា "ការលើកទឹកចិត្តភេរវកម្ម"[108] និង "សកម្មភាពជ្រុលនិយម"[109] ក៏ដូចជាបទល្មើសនៃអំពើភេរវកម្ម "តាមការកោតសរសើរ" "តាមការលើកឲ្យល្បីល្បាញ" ឬ "តាមការធ្វើយុត្តិកម្ម" គួរតែកំណត់ន័យឲ្យបានច្បាស់លាស់ ដើម្បីធានាថា បទល្មើសទាំងនោះ មិននាំឲ្យមានការជ្រៀតជ្រែករំខានដែលមិនចាំបាច់ ឬមិនសមាមាត្រជាមួយនឹងសេរីភាពនៃការបញ្ចេញមតិឡើយ។ ការរិតត្បិតហួសហេតុលើសិទ្ធិទទួលបានព័ត៌មាន ក៏ត្រូវតែជៀសវាងផងដែរ។ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ដើរតួនាទីមួយដ៏សំខាន់ ក្នុងការផ្ដល់ដំណឹងដល់សាធារណៈជនពីអំពើភេរវកម្ម និងសមត្ថភាពរបស់ខ្លួនដើម្បីប្រតិបត្តិការ មិនគួរត្រូវបានរិតត្បិតដោយមិនត្រឹមត្រូវនោះឡើយ។ ហេតុដូចនេះ អ្នកសារព័ត៌មានមិនគួរត្រូវបានដាក់ទោសទណ្ឌ ចំពោះការអនុវត្តសកម្មភាពស្របច្បាប់របស់ខ្លួននោះឡើយ។

៤៧. ច្បាប់បរិហាកេរ្តិ៍ ត្រូវតែបានតាក់តែងដោយយកចិត្តទុកដាក់ ដើម្បីធានាថា ច្បាប់ទាំងនេះ ស្របតាមកថាខ័ណ្ឌ៣ ហើយថា ក្នុងការអនុវត្តជាក់ស្ដែង ច្បាប់ទាំងនេះមិនបំរើដល់ការរិតត្បិតលើសេរី

[108] សូមមើលសេចក្ដីសង្កេតសន្និដ្ឋានសំរាប់សហរាជាណាចក្រនៃចក្រភពអង់គ្លេស និងអៀរឡង់ខាងជើង (CCPR/C/GBR/CO/6)

[109] សូមមើលសេចក្ដីសង្កេតសន្និដ្ឋានសំរាប់សហព័ន្ធរុស្ស៊ី (CCPR/CO/79/RUS)

ភាពនៃការបញ្ចេញមតិឡើយ។[110] ច្បាប់ទាំងឡាយនេះ ជាពិសេស ច្បាប់ដាក់បទបរិហាកេរ្តិ៍ជាបទព្រហ្មទណ្ឌ គួរតែដាក់បញ្ចូលបញ្ញត្តិការពារដូចនេះ ថាជាការការពារតថភាព ហើយមិនគួរត្រូវបានអនុវត្តតាមទម្រង់នៃការបញ្ចេញមតិដែលតាមចរិតលក្ខណៈរបស់វាមិនមែនជាកម្មវត្ថុនៃការពិនិត្យផ្ទៀងផ្ទាត់។ យ៉ាងហោចណាស់ ចំពោះសេចក្តីអធិប្បាយអំពីឥស្សរជនសាធារណៈ គេគួរធ្វើការពិចារណាជៀសវាងការដាក់ទោសទណ្ឌ ឬបើមិនដូច្នេះទេ ដោយការចេញសេចក្តីថ្លែងការណ៍មិនពិតដែលខុសច្បាប់ ដែលត្រូវបានចុះផ្សាយដោយភាន់ច្រឡំ ប៉ុន្តែមិនមានគំនិតព្យាបាទ។[111] ទោះក្នុងករណីណាក៏ដោយ ផលប្រយោជន៍សាធារណៈនៅក្នុងកម្មវត្ថុនៃការរិះគន់ គួរតែត្រូវបានទទួលស្គាល់ថាជាការការពារមួយ។ រដ្ឋភាគី គួរយកចិត្តទុកដាក់ បញ្ចៀសវិធានការ និងទោសទណ្ឌជាទណ្ឌកម្មហួសហេតុ។ ប្រសិនជាពាក់ព័ន្ធ រដ្ឋភាគីគួរដាក់កំហិតសមហេតុផលលើលក្ខខណ្ឌតម្រូវសំរាប់ចុងចោទក្នុងការសងសោហ៊ុយចំណាយដល់ភាគីដែលឈ្នះក្តី។[112] រដ្ឋភាគី គួរពិចារណាអំពីការដកបទបរិហារកេរ្តិ៍ចេញពីបទល្មើសព្រហ្មទណ្ឌ[113] ហើយទោះជាក្នុងករណីណាក៏

110 សូមមើលសេចក្តីសង្កេតសន្និដ្ឋានសំរាប់សហរាជាណាចក្រនៃចក្រភពអង់គ្លេស និងអៀរឡង់ខាងជើង (CCPR/C/GBR/CO/6)

111 ដូចខាងលើ

112 ដូចខាងលើ

113 សូមមើលសេចក្តីសង្កេតសន្និដ្ឋានសំរាប់ប្រទេសអ៊ីតាលី (CCPR/C/ITA/CO/5) និងសេចក្តីសង្កេតសន្និដ្ឋានសំរាប់អតីតសាធារណៈរដ្ឋយូហ្គោស្លាវី ម៉ាសេដូនី (CCPR/C/MKD/CO/2)

ដោយ ការអនុវត្តច្បាប់ព្រហ្មទណ្ឌគួរតែអនុញ្ញាតឲ្យធ្វើចំពោះករណីធ្ងន់ធ្ងរបំផុតប៉ុណ្ណោះ ហើយការដាក់ពន្ធនាគារមិនដែលជាទណ្ឌកម្មសមស្របនោះទេ។ គេមិនអនុញ្ញាតឲ្យរដ្ឋភាគី ចោទប្រកាន់បុគ្គលណាម្នាក់ពីបទបរិហារកេរ្តិ៍ជាបទព្រហ្មទណ្ឌរួចហើយក្រោយមកមិនដំណើរការជំនុំជម្រះឲ្យបានឆាប់រហ័សនោះឡើយ -ការអនុវត្តបែបនេះ មានផលប៉ះពាល់មិនល្អដែលអាចរិតត្បិតមិនត្រឹមត្រូវលើការអនុវត្តសេរីភាពនៃការបញ្ចេញមតិរបស់សាម៉ីជននិងអ្នកដទៃទៀត។[114]

៤៨. បំរាមចំពោះការបង្ហាញពីកង្វះការគោរពដល់សាសនា ឬប្រព័ន្ធជំនឿផ្សេងទៀត រាប់ទាំងច្បាប់ប្រមាថសាសនាផង គឺមិនស្របនឹងកតិកាសញ្ញានេះទេ លើកលែងតែក្នុងកាលៈទេសៈជាក់លាក់ដែលមានចែងក្នុងមាត្រា២០ កថាខ័ណ្ឌទី២នៃកតិកាសញ្ញានេះ។ បំរាមបែបនេះ ក៏ត្រូវតែស្របផងដែរនឹងលក្ខខណ្ឌតម្រូវយ៉ាងតឹងរឹង នៃមាត្រា១៩ កថាខ័ណ្ឌ៣ ព្រមទាំងមាត្រាមួយចំនួន ដូចជាមាត្រា២, ៥, ១៧, ១៨ និងមាត្រា២៦។ ដូច្នេះ ជាឧទាហរណ៍ មិនអនុញ្ញាតចំពោះច្បាប់ទាំងឡាយណាដែលមានការរើសអើង ដោយការគាំទ្រ ឬប្រឆាំងសាសនាមួយ ឬសាសនាជាក់លាក់ ឬប្រព័ន្ធជំនឿ ឬអ្នកកាន់សាសនាមួយ ទៅអ្នកកាន់សាសនាមួយទៀត ឬអ្នកមានជំនឿលើសាសនាមួយទៅអ្នកគ្មានជំនឿលើសាសនា។ វាក៏មិនអនុញ្ញាត

[114] សូមមើលបណ្តឹងលេខ៩០៩/២០០០ រវាង *Kankanamge* និងប្រទេសស្រីលង្កា ទស្សនៈយល់ឃើញអនុម័តកាលពីថ្ងៃទី២៧ កក្កដា ២០០៤។

ឲ្យមានបំរាមបែបនេះ ត្រូវយកមកប្រើប្រាស់ ដើម្បីបង្ការ ឬដាក់ទោសទណ្ឌដល់មតិរិះគន់អ្នកដឹកនាំសាសនា ឬបទអត្ថាធិប្បាយពីលិទ្ធិសាសនា និងគោលការណ៍នៃជំនឿ។[115]

៤៩. ច្បាប់ដែលដាក់ទោសទណ្ឌលើការបញ្ចេញមតិអំពីព្រឹត្តិហេតុជាប្រវត្តិសាស្ត្រ គឺមិនស្របនឹងកាតព្វកិច្ចដែលកតិកាសញ្ញានេះកំណត់ទៅលើរដ្ឋភាគី ទាក់ទងនឹងការគោរពសេរីភាពនៃគំនិត និងការបញ្ចេញមតិនោះទេ។[116] កតិកាសញ្ញានេះ មិនអនុញ្ញាតឲ្យមានបំរាមជាទូទៅ លើការបញ្ចេញមតិដែលភាន់ច្រឡំ ឬការបកស្រាយណាដែលមិនត្រឹមត្រូវ អំពីព្រឹត្តិការណ៍ពីអតីតកាលនោះទេ។ ការរិតត្បិតសិទ្ធិសេរីភាពនៃការបញ្ចេញមតិ មិនគួរត្រូវធ្វើ ហើយការរិតត្បិតទាំងនេះ មិនគួរធ្វើឲ្យហួសពីអ្វីដែលត្រូវបានអនុញ្ញាតក្នុងកថាខ័ណ្ឌទី៣ ឬអ្វីដែលបានតម្រូវក្រោមមាត្រា២០ ឡើយ ទាក់ទងនឹងសេរីភាពនៃការបញ្ចេញមតិ។

[115] សូមមើលសេចក្តីសង្កេតសន្និដ្ឋានសំរាប់សហរាជាណាចក្រនៃចក្រភពអង់គ្លេស និងអៀងឡង់ខាងជើង-ដែនដីរាជាណាចក្រ(CCPR/C/79/Add.119)។សូមមើលផងដែរសេចក្តីសង្កេតសន្និដ្ឋានសំរាប់ប្រទេសគុយវ៉ែត(CCPR/CO/69/KWT) ។

[116] ដែលត្រូវបានហៅថា "ឯកសារច្បាប់ជំនួយស្មារតី" សូមមើលបណ្តឹងលេខ៥៥០/៩៣ រវាង *Faurission* និងប្រទេសបារាំង។ សូមមើលផងដែរសេចក្តីសង្កេតសន្និដ្ឋានសំរាប់ប្រទេសហុងគ្រី(CCPR/HUN/CO/5) វក្យខ័ណ្ឌទី១៩

## ទំនាក់ទំនងរវាងមាត្រា១៩ និងមាត្រា២០

**៥០.** មាត្រា១៩ និងមាត្រា២០ មានលក្ខណៈស្របគ្នា និងបំពេញឲ្យគ្នាទៅវិញទៅមក។ អំពើដែលមានចែងក្នុងមាត្រា២០ សុទ្ធតែស្ថិតនៅក្រោមការរិតត្បិត ស្របតាមមាត្រា១៩ កថាខ័ណ្ឌទី៣។ ដូច្នេះ ការរិតត្បិតណាមួយដែលត្រូវបានធ្វើយុត្តិកម្ម ផ្អែកលើមាត្រា២០ ក៏ត្រូវតែស្របផងដែរនឹងមាត្រា១៩ កថាខ័ណ្ឌទី៣។[117]

**៥១.** អ្វីដែលញែកអំពើដែលមានចែងក្នុងមាត្រា២០ ចេញពីអំពើផ្សេងទៀត ដែលអាចជាកម្មវត្ថុនៃការរិតត្បិតក្រោមមាត្រា១៩ កថាខ័ណ្ឌទី៣ នោះ គឺថា ចំពោះអំពើ ដែលមានចែងក្នុងមាត្រា២០ កតិកាសញ្ញានេះ បង្ហាញពីចំលើយជាក់លាក់ដែលបានតម្រូវពីរដ្ឋមានជាអាទិ៍ បំរាមដោយច្បាប់របស់ខ្លួន។ មានតែស្ថិតក្នុងវិសាលភាពនេះប៉ុណ្ណោះ ដែលមាត្រា២០ អាចត្រូវបានចាត់ទុកថាជា*ច្បាប់ពិសេស* ទាក់ទងនឹងមាត្រា១៩។

**៥២.** មានតែចំពោះទម្រង់ជាក់លាក់នៃការសំដែងមតិដូចបានគូសបញ្ជាក់ក្នុងមាត្រា២០ ថា រដ្ឋភាគីមានកាតព្វកិច្ចដាក់បំរាមតាមផ្លូវច្បាប់។គ្រប់ករណីដែលរដ្ឋធ្វើការរិតត្បិតសេរីភាពនៃការសំដែងមតិ រដ្ឋចាំបាច់ត្រូវបង្ហាញហេតុផលត្រឹមត្រូវ សំរាប់ការហាមប្រាមនោះ និងបទបញ្ញត្តិនានារបស់ខ្លួន ស្របយ៉ាងតឹងរឹងតាមមាត្រា១៩។

៚*៚

[117] សូមមើលបណ្តឹងលេខ៧៣៦/៩៧ រវាង *Ross* និងប្រទេសកាណាដា ទស្សនៈយល់ឃើញអនុម័តកាលពីថ្ងៃទី១៨ តុលា ២០០០។